

ផែនការសកម្មភាពពហុវិស័យ
ស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ
នៅកម្ពុជា ២០២៥-២០២៩

ខែកុម្ភៈ ឆ្នាំ២០២៥

តារាងមាតិកា

បញ្ជីពាក្យជាអក្សរកាត់ iii
សាររបស់ឯកឧត្តមរដ្ឋមន្ត្រី v
សេចក្តីថ្លែងអំណរគុណ vii
សេចក្តីសង្ខេប xi
ជំពូកទី ១៖ សារធាន 13
បញ្ហាប្រឈមជាសកល 14
ការឆ្លើយតបជាសកល 15
បញ្ហាប្រឈមថ្នាក់តំបន់ 16
ការឆ្លើយតបថ្នាក់តំបន់ 16
វិធីសាស្ត្រក្នុងការទប់ស្កាត់ភាពស៊ាំឱសថប្រឆាំងមេរោគរបស់កម្ពុជា 24
ការវាយតម្លៃការអនុវត្តផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ឆ្នាំ២០១៩-២០២៣ 27
ជំពូកទី ២៖ គោលដៅ គោលបំណង និងវត្ថុបំណង 35
គោលដៅ គោលបំណង និងវត្ថុបំណង 36
ជំពូកទី ៣៖ ការបង្កើតផែនការ និងការចូលរួមរបស់តាគីពាក់ព័ន្ធ 38
ជំពូកទី ៤៖ យុទ្ធសាស្ត្រ វត្ថុបំណង និងលទ្ធផលសំខាន់ៗ 40
យុទ្ធសាស្ត្រវត្ថុបំណង និងលទ្ធផលសំខាន់ៗ 41
យុទ្ធសាស្ត្រទី ១៖ អភិបាលកិច្ច និងការសម្របសម្រួលដើម្បីកាត់បន្ថយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ 43
យុទ្ធសាស្ត្រទី ២៖ ការបង្កើតកស្តតាងលើ AMR តាមរយៈការតាមដាន ការស្រាវជ្រាវ និងការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ 51
យុទ្ធសាស្ត្រទី ៣៖ ការប្រើប្រាស់ឱសថប្រឆាំងមេរោគឱ្យបានសមស្រប 66
យុទ្ធសាស្ត្រទី ៤៖ គ្រប់គ្រងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ តាមរយៈការអនុវត្តល្អ 77
យុទ្ធសាស្ត្រទី ៥៖ ការបង្ការ និងគ្រប់គ្រង AMR តាមរយៈការប្រាស្រ័យទាក់ទងហានិភ័យ និងការចូលរួមពីសហគមន៍ 84
ជំពូកទី ៥៖ គោលការណ៍ណែនាំអំពីការអនុវត្តសកម្មភាពផ្សេងៗដែលត្រូវបានកំណត់ក្នុងផែនការសកម្មភាពពហុវិស័យស្តីអំពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ 89
ជំពូកទី ៦៖ ការពិនិត្យតាមដាន និងវាយតម្លៃលើផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ 91

បញ្ជីពាក្យជាអក្សរកាត់

AAR	After Action Review	ពិនិត្យឡើងវិញនូវសកម្មភាពដែលបានអនុវត្ត
AMR	Antimicrobial Resistance	ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ
AMU	Antimicrobial Use	ការប្រើប្រាស់ឱសថប្រឆាំងមេរោគ
AMS	Antimicrobial Stewardship	ការគ្រប់គ្រងការប្រើប្រាស់ឱសថប្រឆាំងមេរោគ
AST	Antimicrobial Susceptibility Testing	ការធ្វើតេស្តប្រសិទ្ធិភាពថ្នាំអង់ទីប៊ីយ៉ូទិក
CDC	Communicable Disease Control	នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
CamLIS	Cambodia Laboratory Information System	ប្រព័ន្ធព័ត៌មានមន្ទីរពិសោធន៍កម្ពុជា
DHS	Department of Hospital Services	នាយកដ្ឋានមន្ទីរពេទ្យ
EQA	External Quality Assurance	ការធានាគុណភាពពីខាងក្រៅ
FAO	Food and Agriculture Organization	អង្គការស្បៀងអាហារ និងកសិកម្ម នៃសហប្រជាជាតិ
GAHP	Good Animal Husbandry Practices	ការអនុវត្តការចិញ្ចឹមសត្វល្អ
GAqP	Good Aquaculture Practices	ការអនុវត្តវារីវប្បកម្មល្អ
GDAHP	General Directorate of Animal Health and Production	អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
GHP	Good Hygiene Practices	ការអនុវត្តអនាម័យល្អ
GLASS	Global Antimicrobial Resistance and Use Surveillance System	ប្រព័ន្ធតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគជាសកល
GMP	Good Manufacturing Practices	ការអនុវត្តការផលិតល្អ
HACCP	Hazard Analysis Critical Control Point	ចំណុចត្រួតពិនិត្យសំខាន់ នៃការវិភាគមហន្តរាយ
IMCC-OH	Inter-Ministerial Coordination Committee for OH	គណៈកម្មការអន្តរក្រសួងសម្រាប់សម្របសម្រួលសុខភាពតែមួយ
IPC	Infection Prevention and Control	ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ
IQC	Internal Quality Control	ការត្រួតពិនិត្យគុណភាពផ្ទៃក្នុង
KAP	Knowledge, Attitudes, and Practices	ចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត
MAFF	Ministry of Agriculture, Forestry and Fisheries	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
M&E	Monitoring and Evaluation	ការពិនិត្យតាមដាន និងវាយតម្លៃ
MEF	Ministry of Economy and Finance	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
MoE	Ministry of Environment	ក្រសួងបរិស្ថាន
MoH	Ministry of Health	ក្រសួងសុខាភិបាល
MoI	Ministry of Interior	ក្រសួងមហាផ្ទៃ
MoJ	Ministry of Justice	ក្រសួងយុត្តិធម៌
MSAP	Multi-Sectoral Action Plan	ផែនការសកម្មភាពពហុវិស័យ
MS AMR TWG	Multi-Sectoral Antimicrobial Resistance Technical Working Group	ក្រុមការងារបច្ចេកទេសពហុវិស័យដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ
NAP	National Action Plan	ផែនការសកម្មភាពជាតិ
NIPH	National Institute of Public Health	វិទ្យាស្ថានជាតិសុខភាពសាធារណៈ
OH	One Health	សុខភាពតែមួយ

PVS	Performance of Veterinary Services	ការអនុវត្តសេវាកម្មបសុសត្វ
RCCE	Risk Communication and Community Engagement	ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមសហគមន៍
RGC	Royal Government of Cambodia	រាជរដ្ឋាភិបាលកម្ពុជា
SOPs	Standard Operating Procedures	នីតិវិធីប្រតិបត្តិស្តង់ដា
SPAR	State Party Self-Assessment Annual Reporting	របាយការណ៍ប្រចាំឆ្នាំស្វ័យវាយតម្លៃរបស់រដ្ឋភាគី
ToR	Terms of Reference	លក្ខខណ្ឌការងារ
TrACSS	Tripartite AMR Country Self-Assessment Survey	ការអង្កេតស្វ័យវាយតម្លៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគត្រីភាគី
UNEP	United Nations Environment Programme	កម្មវិធីបរិស្ថានសហប្រជាជាតិ
US-CDC	United States Centers for Disease Control and Prevention	មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺសហរដ្ឋអាមេរិក
WASH	Water, Sanitation, and Hygiene	ទឹកស្អាត រស់នៅស្អាត និងអនាម័យ
WHO	World Health Organization	អង្គការសុខភាពពិភពលោក
WOAH	World Organisation for Animal Health	អង្គការសុខភាពសត្វពិភពលោក

សាររបស់ឯកឧត្តមរដ្ឋមន្ត្រី

ក្នុងនាមជាក្រសួងពាក់ព័ន្ធតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា យើងប្រកាន់ខ្ជាប់លើការប្តេជ្ញាចិត្តចំពោះវិធីសាស្ត្រសហការគ្រប់ជ្រុងជ្រោយ និងស៊ីសង្វាក់ ដើម្បីឈានទៅបង្ការ និងទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) នៅកម្ពុជាសម្រាប់រយៈពេល ០៥ឆ្នាំចាប់ពីឆ្នាំ២០២៥ ដល់ឆ្នាំ២០២៩។ យើងខ្ញុំសូមបញ្ជាក់សាជាថ្មីថា វិធានការប្រកបដោយចីរភាពប្រឆាំងនឹង AMR បានរួមចំណែកយ៉ាងសំខាន់ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។ យើងទទួលស្គាល់ថា ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ បង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ដែលជាមូលហេតុចម្បងកើតឡើងដោយសារការប្រើប្រាស់ឱសថប្រឆាំងមេរោគមិនសមស្របនៅក្នុងវិស័យសុខភាពមនុស្ស កសិកម្ម និងបរិស្ថាន។

ការអនុវត្តផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (MSAP-AMR) ឆ្នាំ២០១៩-២០២៣ ឆ្លុះបញ្ចាំងពីវឌ្ឍនភាពដ៏សំខាន់ក្នុងការបង្កើនសមត្ថភាពឆ្លើយតបភាពស៊ាំនឹងឱសថប្រឆាំងមេរោគសម្រាប់ជាតិ។ ជាមួយគ្នានេះ គណៈកម្មការអន្តរក្រសួងសម្រាប់សម្របសម្រួលសុខភាពតែមួយ (IMCC-OH) ត្រូវបានបង្កើតដោយបង្ហាញពីសារៈសំខាន់ក្នុងការលើកកម្ពស់ ការឆ្លើយតបរួមគ្នាចំពោះបញ្ហា AMR នៅក្នុងវិស័យផ្សេងៗ។ គណៈកម្មការអន្តរក្រសួងនេះ បាននិងកំពុងពង្រឹងយុទ្ធសាស្ត្រ និងការអនុវត្តប្រកបដោយ ប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហា AMR។

ដោយផ្អែកលើវឌ្ឍនភាពទាំងនេះ យើងទាំងអស់គ្នាពិតជាគាំទ្រដល់ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (MSAP-AMR) សម្រាប់កម្ពុជាឆ្នាំ២០២៥-២០២៩។ ផែនការសកម្មភាពពហុវិស័យនេះបានធ្វើបច្ចុប្បន្នភាពស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា និងផែនការសកម្មភាពសកលស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ គោលដៅរបស់យើងគឺ ដើម្បីកៀរគរធនធានសំខាន់ៗ ក្នុងការអភិវឌ្ឍ និងអនុវត្តនូវយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនានា និងសកម្មភាពដែលបានចែងក្នុង MSAP-AMR នេះ។ ក្នុងការទទួលស្គាល់លើការរួមចំណែកដ៏សំខាន់ដែលត្រូវការចូលរួមពីគ្រប់វិស័យសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព យើងនឹងបន្តការគាំទ្រយ៉ាងមុតមាំលើ IMCC-OH។ IMCC-OH នេះនឹងសម្របសម្រួលតាមដានវឌ្ឍនភាព នៃការអនុវត្តផែនការនេះដើម្បីជានាការឆ្លើយតបរួមគ្នាចំពោះ AMR នៅក្នុងគ្រប់វិស័យពាក់ព័ន្ធ។

យើងខ្ញុំសូមអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់រួមទាំងអង្គភាពរាជរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនគាំទ្រការអនុវត្តផែនការពហុវិស័យនេះ សម្រាប់កម្ពុជាឆ្នាំ២០២៥-២០២៩។ យើងខ្ញុំសូមថ្លែង អំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការរបស់អង្គការសុខភាពពិភពលោក (WHO) អង្គការស្បៀង និងកសិកម្ម

នៃសហប្រជាជាតិ (FAO) អង្គការសុខភាពសត្វពិភពលោក (WOAH) កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) ក៏ដូចជាអង្គការទ្វេភាគី ធនាគារអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់បន្តគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍផែនការសកម្មភាពពហុវិស័យដ៏សំខាន់នេះ។

ថ្ងៃអង្គារ ៤ កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល	រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	រដ្ឋមន្ត្រី ក្រសួងបរិស្ថាន
សាស្ត្រាចារ្យ ឈាង រ៉ា	ឌិត ទីណា	អ៊ាង សុជាល្អែត

សេចក្តីថ្លែងអំណរគុណ

ការចងក្រង នៃផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ សម្រាប់ឆ្នាំ២០២៥-២០២៩ បង្ហាញពីកិច្ចសហការយ៉ាងទូលំទូលាយពីអ្នកជំនាញ និងអង្គការជាច្រើននៅតាមវិស័យផ្សេងៗ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកពាក់ព័ន្ធទាំងអស់ក្នុងការរួមចំណែក ក្នុងការរៀបចំផែនការសកម្មភាពពហុវិស័យនេះ។

I. គណៈកម្មការអន្តរក្រសួងសម្រាប់សម្របសម្រួលសុខភាពតែមួយ

១-	លោកជំទាវវេជ្ជបណ្ឌិត. **យក់ សម្បត្តិ**	រដ្ឋលេខាធិការក្រសួងសុខាភិបាល
២-	ឯកឧត្តម. **សេន សុភណ្ណ**	រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
៣-	ឯកឧត្តមបណ្ឌិត. **សាមូ អូហ្សាណូ**	រដ្ឋលេខាធិការក្រសួងបរិស្ថាន
៤-	ឯកឧត្តមវេជ្ជបណ្ឌិត. **ហុក គីមចេង**	អគ្គនាយកបច្ចេកទេសសុខាភិបាល
៥-	ឯកឧត្តមវេជ្ជបណ្ឌិត. **លី សូវ៉ាន់**	ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ក្រសួងសុខាភិបាល
៦-	លោកស្រីវេជ្ជបណ្ឌិត. **ក្រូច ស៊ីដន**	អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ក្រសួងសុខាភិបាល
៧-	លោកសាស្ត្រាចារ្យ. **ជូ មុនីជារិន**	អគ្គនាយករង ក្រសួងបរិស្ថាន
៨-	លោក. **សុផល ឡាស្ការ**	ប្រធាននាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ ក្រសួងបរិស្ថាន

II. ក្រសួងសុខាភិបាល

១-	ឯកឧត្តមវេជ្ជបណ្ឌិត. **លី សូវ៉ាន់**	ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ក្រសួងសុខាភិបាល
២-	លោកស្រីវេជ្ជបណ្ឌិត. **ក្រូច ស៊ីដន**	អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ក្រសួងសុខាភិបាល
៣-	លោកសាស្ត្រាចារ្យជំនួយ. **ចៅ តារាវ៉ាត្រ**	ប្រធានមន្ទីរពិសោធន៍ជាតិសុខភាពសាធារណៈ
៤-	លោកសាស្ត្រាចារ្យ. **កឹម សាវួន**	អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ
៥-	លោកសាស្ត្រាចារ្យជំនួយ. **យ៉ង់ ជាវ៉ាតុធ**	អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង
៦-	លោកវេជ្ជបណ្ឌិត. **តែ ឱ៉ាន់ថា**	ប្រធានមន្ទីរពេទ្យបង្អែកខេត្តតាកែវ
៧-	លោកវេជ្ជបណ្ឌិត. **ថៃ សាវុធ**	ប្រធានការិយាល័យត្រួតពិនិត្យ និងបង្ការជំងឺឆ្លង នៃនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
៨-	លោកសាស្ត្រាចារ្យជំនួយ. **ហូរ សុថ្ការិទ្ធ**	នាយកមន្ទីរពេទ្យសាកលវិទ្យាល័យ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
៩-	លោកសាស្ត្រាចារ្យ. **ឈ ប៊ុនណា**	អនុប្រធានមន្ទីរពេទ្យកុមារជាតិ
១០-	លោកវេជ្ជបណ្ឌិត. **ណៃ ឡូច**	មន្ត្រីការិយាល័យត្រួតពិនិត្យ និងបង្ការជំងឺឆ្លង នៃនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
១១-	លោកស្រីឱសថបណ្ឌិត. **ឡាយ សុខរក្សា**	មន្ត្រីវិទ្យាស្ថានជាតិសុខភាពសាធារណៈ
១២-	លោកស្រីវេជ្ជបណ្ឌិត. **ភុយ សុផានី**	មន្ត្រីផ្នែកជំងឺទូទៅ "ក" មន្ទីរពេទ្យកាល់ម៉ែត

១៣-	លោកស្រីវេជ្ជបណ្ឌិត. **ជា សេរីវឌ្ឍនា**	មន្ត្រី នៃនាយកដ្ឋានមន្ទីរពេទ្យ

III. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១-	ឯកឧត្តមបណ្ឌិត. **សរ ចិត្រា**	អគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
២-	ឯកឧត្តម. **តាន់ ថាន់ណារ៉ា**	អគ្គនាយក នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
៣-	លោក. **ម៉ឹក គឹមស្រួយ**	អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
៤-	ឯកឧត្តមបណ្ឌិត. **ស៊ន សាន**	ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
៥-	លោកបណ្ឌិត. **ឈៀង ជានី**	អនុប្រធានរដ្ឋបាលព្រៃឈើ
៦-	លោកបណ្ឌិត. **ម៉ាក់ សឿន**	អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម
៧-	លោកបណ្ឌិត. **ទុំ សុច្ឆ៊ីវ**	នាយកវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
៨-	លោក. **ថាយ សុមុនី**	ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
៩-	លោកបណ្ឌិត. **ឆាយ ជីម**	ប្រធាននាយកដ្ឋានកសិឧស្សាហកម្ម
១០-	លោកបណ្ឌិត. **កែ មុន្នីភុធ**	ប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូគាម អនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម
១១-	លោក. **ឆាង សាភុឌ្ឍឌី**	អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
១២-	លោក. **រ័ត្ន ឥចិត្រ**	អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម
១៣-	លោកស្រី. **សារ សុគីរៈ**	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
១៤-	លោក. **ចាប ពិសិដ្ឋ**	អនុប្រធាននាយកដ្ឋានបច្ចេកទេសវិទ្យាកែច្នៃ និងគុណភាព នៃរដ្ឋបាលជលផល
១៥-	លោក. **ឈាង សុភក្ត្រា**	អនុប្រធាននាយកដ្ឋាន នៃរដ្ឋបាលព្រៃឈើ
១៦-	លោកស្រីបណ្ឌិត. **ជួន មណីរដ្ឋ**	ប្រធានមន្ទីរពិសោធន៍ ផលិតផលកសិកម្ម និងចំណីអាហារកម្ពុជា នៃនាយកដ្ឋានកសិ ឧស្សាហកម្ម
១៧-	លោក. **ខាន់ ច័ន្ទតារា**	ប្រធានការិយាល័យគ្រប់គ្រងជំងឺ និងសុខភាពវារីសត្វ នៃរដ្ឋបាលជលផល
១៨-	លោកបណ្ឌិត. **មាយ ប្រមូល**	ប្រធានការិយាល័យគ្រប់គ្រងចំណីសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
១៩-	លោក. **ប៉ាង ថានិត**	អនុប្រធានការិយាល័យ នៃរដ្ឋបាលព្រៃឈើ
២០-	លោក. **ភណ្ណ ឌីឥន**	អនុប្រធានការិយាល័យ នៃរដ្ឋបាលព្រៃឈើ
២១-	លោកបណ្ឌិត. **ឆូវ សុភ័ណ**	អនុប្រធានការិយាល័យ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
២២-	លោកបណ្ឌិត. **ភុិន ភុត្តី**	មន្ត្រី នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
២៣-	លោកបណ្ឌិត. **ជា ប៊ុនណា**	គ្រូបង្រៀន នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
២៤-	លោក. **ជា សុគន្ធ**	អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានកិច្ចការរដ្ឋបាល
២៥-	លោក. **ជា សុវណ្ណារ៉ា**	អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានសុខភាពសត្វ

		និងផលិតកម្មសត្វ
២៦-	លោកបណ្ឌិត. **ជា រតនា**	អនុប្រធានមន្ទីរពិសោធន៍ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
២៧-	លោក. **ស៊ាក់ តាព**	មន្ត្រី នៃនាយកដ្ឋានកិច្ចការរដ្ឋបាល

IV. ក្រសួងបរិស្ថាន

១-	ឯកឧត្តមបណ្ឌិត. **សាមូ អូហ្សាណូ**	រដ្ឋលេខាធិការ ក្រសួងបរិស្ថាន
២-	លោកសាស្ត្រាចារ្យ. **ជូ មុនីជារិន**	អគ្គនាយករង ក្រសួងបរិស្ថាន
៣-	លោក. **សុផល ឡាស្ការ**	ប្រធាននាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ ក្រសួងបរិស្ថាន
៤-	លោកបណ្ឌិត. **ជែក ឥមានតក្តី**	អនុប្រធាននាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់
៥-	លោក. **តែម សុខចាន់**	ប្រធានការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់
៦-	កញ្ញា. **ហួត ស៊ីវ៉ាដែត**	ប្រធានការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងគុណភាពទឹក
៧-	លោក. **សួន ពន្លក**	អនុប្រធានការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់
៨-	កញ្ញា. **ឆួន រីដូ**	អនុប្រធានការិយាល័យ នៃមន្ទីរពិសោធន៍
៩-	កញ្ញា. **យិន ឥលក្ខណ៍**	អនុប្រធានការិយាល័យ នៃមន្ទីរពិសោធន៍
១០-	លោកបណ្ឌិត. **ស៊ុម សាមុត**	មន្ត្រីបច្ចេកទេស នៃនាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់

V. ដៃគូអភិវឌ្ឍន៍

១-	លោកវេជ្ជបណ្ឌិត. **សារីកា ប៉ាតែល**	មន្ត្រីបច្ចេកទេស អង្គការសុខភាពពិភពលោក
២-	លោក. **រៀង ឥណ្ណា**	មន្ត្រីបច្ចេកទេស អង្គការសុខភាពពិភពលោក
៣-	លោកស្រី. **លីហ្សា ស្ទឹត**	មន្ត្រីបច្ចេកទេស អង្គការសុខភាពពិភពលោក
៤-	លោក. **ឆៅ ឥណ្ណជារិទ្ធិ**	អ្នកសម្របសម្រួលគម្រោង AMR អង្គការសុខភាពពិភពលោក
៥-	លោកបណ្ឌិត. **ហាក់ មករា**	ទីប្រឹក្សាបច្ចេកទេស អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ
៦-	លោកវេជ្ជបណ្ឌិត. **អាលីហ្សា ហ្វាំងឡេ**	តំណាងមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺសហរដ្ឋអាមេរិក
៧-	លោកវេជ្ជបណ្ឌិត. **ប៊ុន ស្រេង**	តំណាងមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺសហរដ្ឋអាមេរិក
៨-	លោកវេជ្ជបណ្ឌិត. **អេម៉ាញ្ចូអេល អ៊ីវ៉ាលី**	តំណាងអ្នកប្រឹក្សាយោបល់ទីភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់
៩-	លោកវេជ្ជបណ្ឌិត. **បេតទីណា រូហោ**	តំណាងទីភ្នាក់ងារសហប្រតិបត្តិការ អាល្លឺម៉ង់
១០-	លោកវេជ្ជបណ្ឌិត. **អ៊ឹង ព្រហស្បតិ**	តំណាងទីភ្នាក់ងារសហប្រតិបត្តិការ អាល្លឺម៉ង់
១១-	លោកវេជ្ជបណ្ឌិត. **ជួង ស៊ីឃុល**	តំណាងទីភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់
១២-	លោកវេជ្ជបណ្ឌិត. **ប៉ូល ច័ន្ទរ**	តំណាងមន្ទីរពេទ្យកុមារអង្គរ
១៣-	លោកវេជ្ជបណ្ឌិត. **មីលីយ៉ា ធីល**	តំណាងមន្ទីរពេទ្យកុមារអង្គរ


យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកក្រុមការងារបច្ចេកទេសដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នៃក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ដែលបានជួយគាំទ្រដល់ការអភិវឌ្ឍផែនការពហុវិស័យនេះ និងអង្គការដៃគូរួមមាន WHO FAO WOAH UNEP GIZ KfW និងធនាគារពិភពលោក សម្រាប់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។

សេចក្តីសង្ខេប

ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅកម្ពុជា ២០២៥-២០២៩ ដាក់ចេញនូវយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយដើម្បីដោះស្រាយការគំរាមកំហែងភាពស៊ាំនឹងឱសថប្រឆាំងមេរោគដែលកំពុងតែកើនឡើងតាមរយៈអភិក្រមសុខភាពតែមួយដែលគ្របដណ្តប់លើវិស័យសុខភាពមនុស្ស សុខភាពសត្វ អាហារ រុក្ខជាតិ និងសុខភាពបរិស្ថាន។ ផែនការនេះត្រូវបានបង្កើតឡើងដោយឈរលើយុទ្ធសាស្ត្រឆ្នាំ ២០១៩-២០២៣ (MSAP-AMR ២០១៩-២០២៣) សំដៅរួមបញ្ចូលកិច្ចខិតខំប្រឹងប្រែងនានា នៅលើគ្រប់វិស័យដើម្បីបង្កើតការឆ្លើយតបរួមគ្នាមួយចំពោះភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នៅតែជាបញ្ហាប្រឈមផ្នែកសុខភាព និងការអភិវឌ្ឍសកលដ៏សំខាន់មួយ ជាមួយនឹងការប្រើប្រាស់មិនសមស្រប និងការប្រើប្រាស់ឱសថប្រឆាំងមេរោគលើសកម្រិត នៅទូទាំងវិស័យផ្សេងៗ ដែលបង្កើនល្បឿន នៃភាពស៊ាំដែលធ្វើឱ្យការបង្ករោគកាន់តែពិបាកព្យាបាល។ នៅទូទាំងពិភពលោក ភាពស៊ាំនឹងឱសថប្រឆាំងមេរោគទទួលខុសត្រូវដោយផ្ទាល់ចំពោះការស្លាប់ប្រហែល ១.២៧លាននាក់ក្នុងមួយឆ្នាំ។ ផលប៉ះពាល់លើសេដ្ឋកិច្ចមានលក្ខណៈស៊ីជម្រៅ ជាមួយនឹងសក្តានុពលចំណាយលើការថែទាំសុខភាព និងការខាតបង់ផលិតផលក្នុងស្រុកសរុបត្រូវបានព្យាករណ៍ថានឹងកើនឡើងទៅដល់រាប់ពាន់ពាន់លានដុល្លារ នៅដំណាច់ឆ្នាំ២០៥០។ យុទ្ធសាស្ត្រសកលដែលគាំទ្រដោយអង្គការនានា ដូចជា WHO និង FAO សង្កត់ធ្ងន់លើវិធីសាស្ត្រពហុវិស័យ និងសម្របសម្រួលនៅក្រោមឆត្រសុខភាពតែមួយដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យ នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគប្រកបដោយប្រសិទ្ធភាព។

ព្រះរាជាណាចក្រកម្ពុជាបានធ្វើឱ្យប្រសើរឡើងគួរឱ្យកត់សម្គាល់នូវសូចនាករសុខភាព និងការអភិវឌ្ឍរបស់ខ្លួនក្នុងចិរវេលាប៉ុន្មានឆ្នាំចុងក្រោយនេះប៉ុន្តែភាពស៊ាំនឹងឱសថប្រឆាំងមេរោគ បានបង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដែលមានសមត្ថភាពនាំភាពប្រសើរទាំងនេះត្រលប់ថយក្រោយវិញ។ ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ២០២៥-២០២៩ ត្រូវបានរៀបចំឡើងជុំវិញផែនយុទ្ធសាស្ត្រចំនួន ៥៖



ផែនយុទ្ធសាស្ត្រនីមួយៗមានអន្តរាគមន៍គោលដៅជាច្រើនដែលត្រូវបានរៀបចំឡើងដើម្បីដោះស្រាយទិដ្ឋភាពជាក់លាក់ នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ សរុបជាង ១៧០ សកម្មភាពលម្អិតនៅក្នុងផែនការទាំងមូលសម្រាប់រយៈពេល ០៥ឆ្នាំ។

ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នេះជាលើកដំបូងដែលមានផែនការបែបនេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានរួមបញ្ចូលគម្រោងថវិកាសរុបប្រមាណជា ១៧,២៤៦,០០០ ដុល្លារអាមេរិក។ វាគឺជាឧបករណ៍សំខាន់មួយសម្រាប់ការកៀរគរធនធានសំដៅជានាមូលនិធិពីអ្នកផ្តល់ជំនួយពីខាងក្រៅ និងថវិកាជាតិ។ ផែនការថវិកានេះមានសារៈសំខាន់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រនានាដែលបានគ្រោងទុកប្រកបដោយប្រសិទ្ធភាព។

ឯកសារនេះត្រូវបានគ្រោងជាចម្បងសម្រាប់អ្នកធ្វើសេចក្តីសម្រេច នៅគ្រប់ក្រសួងជាច្រើន រួមទាំងក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ព្រមទាំងក្រសួងបរិស្ថាន ដែលជាក្រសួងគន្លឹះក្នុងការឆ្លើយតបថ្នាក់ជាតិចំពោះភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ លើសពីនេះ វាបម្រើជាឯកសារយោងដ៏សំខាន់សម្រាប់ដៃគូអភិវឌ្ឍន៍ និងអ្នកផ្តល់ជំនួយនានាដោយវាផ្តល់នូវក្របខ័ណ្ឌច្បាស់លាស់សម្រាប់កិច្ចសហការ និងការគាំទ្រផ្នែកហិរញ្ញវត្ថុ។

ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅកម្ពុជា២០២៥-២០២៩ បង្ហាញពីវិធីសាស្ត្រជាយុទ្ធសាស្ត្រ និងបែបរួមបញ្ចូលក្នុងការគ្រប់គ្រងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ជាមួយនឹងគោលបំណងត្រូវបានកំណត់យ៉ាងច្បាស់ អន្តរាគមន៍ជាក់លាក់ និងផែនការថវិកាលម្អិត។ យុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយបែបនេះដោះស្រាយបញ្ហាប្រឈមផ្នាល់នានា ដែលបង្កឡើងដោយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងស្របតាមអាទិភាពសុខភាពសកលដើម្បីការពារវឌ្ឍនភាពសុខភាពរបស់កម្ពុជា។ ការអនុវត្តប្រកបដោយជោគជ័យ នៃផែនការនេះនឹងពឹងផ្អែកលើការចូលរួមដោយប្តេជ្ញាចិត្តរបស់អ្នកពាក់ព័ន្ធទាំងអស់ដោយសង្កត់ធ្ងន់លើសារៈសំខាន់ នៃការឆ្លើយតបប្រកបដោយឯកភាព និងការឆ្លើយតបដោយមានធនធានគ្រប់គ្រាន់ចំពោះវិបត្តិនៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ជំពូកទី ១

សារធាន

បញ្ហាប្រឈមជាសកល

ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ជាការគំរាមកំហែងផ្នែកសុខភាពសាធារណៈ និងអភិវឌ្ឍន៍ជាសកល គួរឱ្យភ័យខ្លាចមួយ។ ក្នុងឆ្នាំ២០១៩ បាក់តេរីដែលស៊ាំនឹងឱសថប្រឆាំងមេរោគ ទទួលខុសត្រូវដោយផ្ទាល់ចំពោះការស្លាប់ប្រមាណ ១.២៧លាននាក់ និងមានអ្នកជំងឺស្លាប់ដែលពាក់ព័ន្ធជាមួយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ប្រមាណជា ៤.៩៥ លាននាក់។ ការប្រើប្រាស់មិនសមស្រប និងលើសកម្រិតរបស់ឱសថប្រឆាំងមេរោគលើមនុស្ស សត្វ និងរុក្ខជាតិ គឺជាកត្តាចម្បងបណ្តាលឱ្យមានមេរោគស៊ាំនឹងឱសថ និងនាំទៅដល់ស្ថានភាពមួយដែលសូម្បីតែនីតិវិធីវេជ្ជសាស្ត្រ និងការព្យាបាលស្តង់ដាក៏កាន់តែមានគ្រោះថ្នាក់ផងដែរ។

ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ មិនត្រូវបានកំណត់ដោយព្រំដែនភូមិសាស្ត្រ ឬសេដ្ឋកិច្ចទេ បង្កផលប៉ះពាល់ដល់គ្រប់តំបន់ និងកម្រិតចំណូល។ ផលប៉ះពាល់របស់វាគឺធ្ងន់ធ្ងរ ជាពិសេសនៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម។ ប្រទេសដែលមានភាពក្រីក្រ និងវិសមភាពនឹងទទួលរងផលប៉ះពាល់ពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគកាន់តែធ្ងន់ធ្ងរ។ បញ្ហាប្រឈមជាសាកលនេះ គំរាមកំហែងដល់ភាពរីកចម្រើនសំខាន់ៗ ដែលត្រូវបានធ្វើឡើងនៅក្នុងវេជ្ជសាស្ត្រទំនើបបង្កផលវិបាកដល់ការព្យាបាល នៃការបង្ករោគ និងបង្កើនហានិភ័យនានាដែលទាក់ទងនឹងការវះកាត់ព្រមទាំងការព្យាបាលជំងឺមហារីក។

ខាងផ្នែកសេដ្ឋកិច្ច ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ បង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដោយមានការព្យាករណ៍ថាការចំណាយលើការថែទាំសុខភាពឡើងដល់ ១ពាន់លានដុល្លារអាម៉េរិក នៅឆ្នាំ២០៥០ និងការខាតបង់ផលិតផលជាតិសរុប (GDP) ប្រចាំឆ្នាំក្នុងចន្លោះពី ១ពាន់ ទៅ ៣.៤ពាន់លានដុល្លារអាមេរិក នៅឆ្នាំ២០៣០។ ដើម្បីដោះស្រាយបញ្ហានេះ អាទិភាពនានារួមមានការការពារ ការបង្ករោគដែលនាំទៅដល់ការប្រើប្រាស់មិនសមស្រប នៃឱសថប្រឆាំងមេរោគ ដើម្បីធានានូវការគ្របដណ្តប់ជាសកលនូវការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលប្រកបដោយគុណភាពព្រមទាំងបង្កើនព័ត៌មានយុទ្ធសាស្ត្រ និងនវានុវត្តន៍ ដូចជាការអង្កេតតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងការប្រើប្រាស់ឱសថប្រឆាំងមេរោគ ការបង្កើតវ៉ាក់សាំងការធ្វើរោគវិនិច្ឆ័យ និងផលិតឱសថថ្មីៗ ជាដើម។

ការកើនឡើង នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគជាសកលកំពុងកាត់បន្ថយប្រសិទ្ធភាពរបស់ថ្នាំអង់ទីប៊ីយ៉ូទិកដែលប្រើប្រាស់ជាទូទៅសម្រាប់ទប់ស្កាត់ការរីករាលដាល នៃការបង្ករោគដោយបាក់តេរី។ របាយការណ៍ប្រព័ន្ធតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគជាសកល ឆ្នាំ ២០២៣ (GLASS) ចង្អុលទៅអត្រាភាពស៊ាំគួរឱ្យព្រួយបារម្ភក្នុងចំណោមភ្នាក់ងារបាក់តេរីបង្ករោគ។ ជាឧទាហរណ៍ អត្រាភាពស៊ាំទៅនឹង cephalosporin ជំនាន់ទី ៣ នៅក្នុង *Escherichia coli (E. coli)* និង ក្នុង *Staphylococcus aureus* ដែលស៊ាំនឹង methicillin (MRSA) គឺគួរឱ្យព្រួយបារម្ភជាខ្លាំង។ ក្នុងឆ្នាំ ២០២០ ការបង្ករោគដោយមេរោគលើផ្លូវបង្ហូរនោម ដែលបង្កឡើងដោយ *E. coli* បានបង្ហាញពីក្តីព្រួយបារម្ភ ដោយសារការថយចុះ នៃភាពងាយមានប្រសិទ្ធភាពរបស់ឱសថអង់ទីប៊ីយូទិកស្តង់ដា ដូចជា ampicillin និង fluoroquinolones។

លើសពីនេះ មេរោគ *Klebsiella pneumoniae* ដែលជាធម្មតាត្រូវបានរកឃើញនៅក្នុងពោះវៀនកំពុងបង្ហាញពីការកើនឡើង នៃកម្រិតភាពស៊ាំ ជាមួយនឹងឱសថអង់ទីប៊ីយ៉ូទិកសំខាន់ៗ ដែលនាំឱ្យមានការពឹងផ្អែកកាន់តែខ្លាំងទៅលើឱសថចុងក្រោយដូចជា carbapenems។ ទោះជាយ៉ាងណាក៏ដោយ ភាពស៊ាំនឹងឱសថទាំងនេះក៏កំពុងកើនឡើងផងដែរ។ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ប្រមើលមើលកំណើនទ្វេដង នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគចុងក្រោយបំផុតទាំងនេះនៅឆ្នាំ២០៣៥

បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៥ ដោយបានគូសបញ្ជាក់អំពីតម្រូវការបន្ទាន់សម្រាប់ការអនុវត្តការគ្រប់គ្រងឱសថប្រឆាំងមេរោគ និងការបង្កើនការអង្កេតតាមដាន។

ការឆ្លើយតបជាសកល

ការប្រយុទ្ធប្រឆាំងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ទាមទារឱ្យមានការឆ្លើយតបជាសាកលប្រកបដោយឯកភាព និងសម្របសម្រួលដោយទទួលស្គាល់ភាពស្មុគស្មាញនៃបញ្ហាដែលលាតសន្ធឹងលើវិស័យផ្សេងៗ ដូចជា វិស័យសុខភាពមនុស្ស ផលិតកម្មចំណីអាហារ សុខភាពសត្វ និងការថែទាំបរិស្ថាន។ វិធីសាស្ត្រនេះហៅថា វិធីសាស្ត្រសុខភាពតែមួយ ដែលជាចំណុចសំខាន់ក្នុងការដោះស្រាយភាពស៊ាំនឹងឱសថប្រឆាំងមេរោគប្រកបដោយប្រសិទ្ធភាព។ វិធីសាស្ត្រនេះជំរុញរួមបញ្ចូលតែមួយសំដៅទទួលបាននូវលទ្ធផលសុខភាពប្រកបដោយចីរភាពសម្រាប់មនុស្ស សត្វ និងប្រព័ន្ធអេកូសាស្ត្រ ការយល់ដឹងអំពីភាពអាស្រ័យគ្នាទៅវិញទៅមកនៃសុខភាពមនុស្ស សុខភាពសត្វស្រុក និងសត្វព្រៃ រុក្ខជាតិ និងបរិស្ថាន។

ដើម្បីដាក់វិធីសាស្ត្រនេះជាផ្លូវការ ផែនការសកម្មភាពសកលស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគត្រូវបានអនុម័តក្នុងអំឡុងសន្និបាតសុខភាពពិភពលោកឆ្នាំ២០១៥។ ផែនការនេះក្រោយមកត្រូវបានអនុម័តដោយអង្គការអន្តរជាតិសំខាន់ៗ ដូចជា FAO WOAH និងUNEP ដែលបានសង្កត់ធ្ងន់លើការអភិវឌ្ឍ និងការអនុវត្តផែនការសកម្មភាពជាតិ ពហុវិស័យជាមួយនឹងទស្សនវិស័យសុខភាពតែមួយ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នានេះ គឺក្នុងគោលបំណងដោះស្រាយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងទទួលបាននូវលទ្ធផលសុខភាព និងសេដ្ឋកិច្ចប្រសើរឡើងក្នុងពេលនោះផងដែរ។

សមាសធាតុសំខាន់មួយនៅក្នុងកិច្ចខិតខំប្រឹងប្រែងប្រកបដោយកិច្ចសម្របសម្រួលនេះ គឺលេខាធិការដ្ឋានរួមចតុកាគីសម្រាប់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ រួមមាន WHO, FAO, WOAH និងUNEP។ លេខាធិការដ្ឋាននេះជាឧបករណ៍ក្នុងការដឹកនាំឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធច្រើននៅក្នុងការងារភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងបានគាំទ្រដល់ការបង្កើតក្រុមអ្នកដឹកនាំសកលធ្វើការលើភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងវេទិកាភាពជាដៃគូពហុភាគី។ គំនិតផ្តួចផ្តើមទាំងនេះ រួមជាមួយនឹងក្រុមការងារបច្ចេកទេសជាច្រើនបានចាប់ផ្តើមការងាររបស់ពួកគាត់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដែលនាំមកនូវវឌ្ឍនភាពដ៏សំខាន់នៅក្នុងការប្រយុទ្ធជាសកលប្រឆាំងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

លើសពីនេះ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/៧៦/២៥៧ ដែលបានអនុម័តក្នុងខែមីនា ឆ្នាំ២០២២ បានកំណត់ដំណាក់កាលសម្រាប់កិច្ចប្រជុំកម្រិតខ្ពស់លើកទី២ ស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដែលបានប្រព្រឹត្តទៅនៅឆ្នាំ២០២៤។ កិច្ចប្រជុំនេះបង្ហាញពីឱកាសដ៏សំខាន់មួយសម្រាប់ប្រទេសនានាក្នុងការបង្កើតការប្តេជ្ញាចិត្តប្រកបដោយមហិច្ឆតា និងកំណត់ចំណុចដៅនានាដើម្បីប្រយុទ្ធប្រឆាំងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ការឆ្លើយតបជាសាកលចំពោះភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ផ្តោតលើកិច្ចខិតខំប្រឹងប្រែងពហុវិស័យរួមផ្សំសកម្មភាព និងយុទ្ធសាស្ត្រនៅទូទាំងវិស័យមនុស្ស សត្វ កសិកម្ម និងបរិស្ថាន។ វិធីសាស្ត្របែបសហការនេះដោះស្រាយបញ្ហាប្រឈមនានាក្នុងពេលបច្ចុប្បន្ន និងត្រួសត្រាយផ្លូវសម្រាប់ដំណោះស្រាយ និងគោលនយោបាយសុខភាពប្រកបដោយនិរន្តរភាពពង្រឹងតួនាទីដ៏សំខាន់ នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការសម្របសម្រួលក្នុងវិស័យសុខភាពសាធារណៈ។

បញ្ហាប្រឈមថ្នាក់តំបន់

តំបន់ប៉ាស៊ីហ្វិកខាងលិចជួបប្រទះបញ្ហាប្រឈមដ៏សំខាន់មួយជាមួយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ បញ្ហាប្រឈមនេះត្រូវបានរំពឹងថានឹងបង្កឱ្យមានអ្នកស្លាប់ប្រមាណជា ៥.២លាននាក់ នៅដំណាច់ឆ្នាំ២០៣០។ ស្ថិតិដ៏ព្រួយបារម្ភណ៍នេះ បានមកពីការវាយតម្លៃថ្នាក់តំបន់ដំបូងរបស់អង្គការសុខភាពពិភពលោក ស្តីពីផលប៉ះពាល់សុខភាព និងសេដ្ឋកិច្ច នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នៅក្នុងតំបន់នេះដែលត្រូវបានចេញផ្សាយក្នុងខែមិថុនា ឆ្នាំ២០២៣។ ការវាយតម្លៃនេះ ក៏បានបង្ហាញផងដែរថា ភាពស៊ាំនឹងឱសថប្រឆាំងមេរោគនឹងមានឥទ្ធិពលបំផ្លិចបំផ្លាញដល់សុខភាព និងទម្លាក់បន្ទុកសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរមួយដែលត្រូវចំណាយក្នុងតំបន់ក្នុងរង្វង់ ១៤៨ពាន់លានដុល្លារអាមេរិក ចន្លោះពីឆ្នាំ២០២០ ដល់ឆ្នាំ២០៣០។ តួលេខនេះតំណាងឱ្យជិត១០% នៃការចំណាយលើសុខភាពសរុបក្នុងតំបន់ក្នុងឆ្នាំ២០១៩ ដោយសារការបាត់បង់ផលិតភាព និងការចំណាយលើការថែទាំសុខភាពបន្ថែមបណ្តាលមកពីការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យរយៈពេលយូរ។ នៅដំណាច់ឆ្នាំ២០៣០ អ្នកជំងឺដែលមានការបង្ករោគដោយមេរោគស៊ាំនឹងឱសថប្រឆាំងមេរោគ ត្រូវបានគេព្យាករណ៍ថានឹងចំណាយពេល ១៧២លានថ្ងៃបន្ថែមនៅក្នុងមន្ទីរពេទ្យ។

របាយការណ៍ «ផលប៉ះពាល់លើសុខភាព និងសេដ្ឋកិច្ច នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅក្នុងតំបន់ប៉ាស៊ីហ្វិកខាងលិច ២០២០-២០៣០[1]» រាយការណ៍ដោយ WHO នៅក្នុងតំបន់ប៉ាស៊ីហ្វិកខាងលិច រំលេចលក្ខណៈសំខាន់ នៃ «ជំងឺរាតត្បាតស្ងប់ស្ងាត់» នេះ។ ក្នុងឆ្នាំ២០២០ មរណភាពដែលបង្កឡើងដោយភាពស៊ាំនឹងឱសថប្រឆាំងមេរោគក្នុងតំបន់បានកើនលើសមរណភាពដែលបង្កដោយជំងឺរបេង ឬមេរោគអេដស៍ ជាមួយនឹងចំនួនប្រហាក់ប្រហែលទៅនឹងមរណភាពដោយសារជំងឺទឹកនោមផ្អែម ជំងឺក្រិនថ្លើម និងមហារីកសុដន់។ របាយការណ៍នេះបានរំលេចចេញបាក់តេរីបង្ករោគសំខាន់ៗចំនួន៧ ដូចជា MRSA និង *E. coli* ដែលត្រូវបានព្យាករណ៍ថានឹងទទួលខុសត្រូវចំពោះមរណភាពពាក់ព័ន្ធជាង ៨០% នៅក្នុងទសវត្សរ៍ខាងមុខនេះ។

ការឆ្លើយតបថ្នាក់តំបន់

ដោះស្រាយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ គឺជាអាទិភាពសំខាន់នៅក្នុងតំបន់ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងចក្ខុវិស័យ នៃ «សម្រាប់អនាគត៖ ឆ្ពោះទៅកាន់តំបន់ដែលមានសុខភាពប្រសើរ និងមានសុវត្ថិភាពបំផុត» ដែលសំដៅធ្វើឱ្យប៉ាស៊ីហ្វិកខាងលិចក្លាយជាតំបន់របស់ពិភពលោក ដែលមានសុខភាពប្រសើរ និងមានសុវត្ថិភាពបំផុត។ ក្របខ័ណ្ឌតំបន់សម្រាប់ពន្លឿនសកម្មភាពដើម្បីប្រយុទ្ធប្រឆាំងនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ គូសបញ្ជាក់អំពីយុទ្ធសាស្ត្រមួយរបស់ WHO ដោយសហការជាមួយរដ្ឋជាសមាជិកដើម្បីកាត់បន្ថយផលប៉ះពាល់របស់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ[2]។ ទោះជាយ៉ាងណាក៏ដោយ វឌ្ឍនភាពត្រូវបានរារាំងដោយទិន្នន័យមិនសមស្រប។ របាយការណ៍នេះគូសបង្ហាញពីជំហានដ៏សំខាន់មួយ ក្នុងការផ្តល់បទអន្តរាគមន៍នានាប្រកបដោយប្រសិទ្ធភាព ប្រឆាំងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងការតស៊ូមតិសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវការប្រមូលទិន្នន័យ ដើម្បីស្វែងយល់ពីការគំរាមកំហែង នាពេលអនាគត កាន់តែត្រឹមត្រូវ។

បណ្តាប្រទេសទាំងឡាយនៅក្នុងតំបន់នេះ ដូចជាព្រះរាជាណាចក្រកម្ពុជា ត្រូវបានស្នើយ៉ាងទទូចឱ្យពន្លឿនការអនុវត្តការពិនិត្យតាមដាន និងការពិនិត្យកែលម្អនូវផែនការសកម្មភាពជាតិអំពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ការងារនេះតម្រូវឱ្យមានការបែងចែកថវិកា និងធនធានមនុស្សគ្រប់គ្រាន់ ការពង្រឹងប្រព័ន្ធជាតិតាមអង្កេតតាមដាន

[1] WHO WPRO, Health and Economic Impacts of Antimicrobial Resistance in the Western Pacific Region 2020-2030.

[2] WHO WPRO, Framework for Accelerating Action to Fight Antimicrobial Resistance.

ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ការលើកកម្ពស់ការគ្រប់គ្រងឱសថប្រឆាំងមេរោគសមស្រប ដើម្បីកាត់បន្ថយការប្រើប្រាស់លើសកម្រិត និងការប្រើប្រាស់មិនត្រឹមត្រូវព្រមទាំងការកែលម្អការបង្ការ និងត្រួតពិនិត្យការចម្លងរោគ។ ការវិនិយោគលើការគ្រប់គ្រង និងប្រយុទ្ធប្រឆាំងភាពស៊ាំនឹងឱសថប្រឆាំងមេរោគឥឡូវនេះ នឹងជួយសន្សំសំចៃថ្លៃចំណាយថែទាំសុខភាព នាពេលអនាគត ការពារកម្លាំងពលកម្ម និងការពារសេដ្ឋកិច្ចដោយសង្កត់ធ្ងន់លើតម្រូវការសម្រាប់គោលនយោបាយ និងការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុសមាមាត្រទៅនឹងផលប៉ះពាល់ពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ស្ថានភាពសុខភាពទូទៅ និងការអភិវឌ្ឍរបស់កម្ពុជា និងសារៈសំខាន់ នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ

ព្រះរាជាណាចក្រកម្ពុជាបានសម្គាល់ឃើញមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងផ្នែកស្ថានភាពសុខភាពទូទៅ និងការអភិវឌ្ឍរបស់ខ្លួនក្នុងរយៈពេល ៥ឆ្នាំកន្លងទៅនេះ។ វឌ្ឍនភាពនេះនាំមកដោយកំណើនស្ថេរភាពសេដ្ឋកិច្ចដែលអាចបកស្រាយតាមការកាត់បន្ថយភាពក្រីក្រ និងជីវភាពស្តង់ដាប្រសើរឡើងសម្រាប់ប្រជាជនកម្ពុជាជាច្រើន។ លើសពីនេះទៅទៀតក្នុងពេលបច្ចុប្បន្នប្រជាជនកម្ពុជាទទួលបានសេវាថែទាំសុខភាពសារវន្តកាន់តែច្រើនព្រមទាំងមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់នូវមរណភាពកុមារ និងជំងឺឆ្លងនានា[3]។

លទ្ធផលសុខភាពជាវិជ្ជមាន

អាយុសង្ឃឹមរស់នៅកម្ពុជាបានកើនឡើងពីរឆ្នាំក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ គឺកើនពី៦៤.៥ឆ្នាំ ក្នុងឆ្នាំ២០១៨ ទៅដល់ ៦៦.៥ឆ្នាំ ក្នុងឆ្នាំ ២០២៣[4]។ ភាពប្រសើរឡើងនេះ បានមកពីកត្តាជាច្រើន រួមមានការទទួលបានសេវាថែទាំសុខភាពកាន់តែប្រសើរ អាហារូបត្ថម្ភកាន់តែប្រសើរ និងការកើនឡើង នៃការអភិវឌ្ឍសេដ្ឋកិច្ច[5]។

ការទទួលបានសេវាថែទាំសុខភាពកាន់តែប្រសើរ

ភាគរយ នៃប្រជាជនកម្ពុជាដែលបានទទួលសេវាថែទាំសុខភាពបានកើនឡើងពី ៧៥% ក្នុងឆ្នាំ២០១៨ ទៅដល់ ៨៥% ក្នុងឆ្នាំ២០២៣[6]។ កំណើននេះ បានមកពីកត្តាជាច្រើនរួមមានការសាងសង់មន្ទីរពេទ្យថ្មីៗ និងគ្លីនិកថ្មីៗ ការពង្រីកការគ្របដណ្តប់ធានារ៉ាប់រងសុខភាព និងការបណ្តុះបណ្តាលដល់បុគ្គលិកថែទាំសុខភាពកាន់តែច្រើន[7]។

ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ២០២១-២០២២ បង្ហាញពីភាពប្រសើរឡើងគួរឱ្យកត់សម្គាល់លើសុខភាពមាតា និងទារក នៅទូទាំងប្រទេស។ អត្រាមរណភាពមាតាបានធ្លាក់ចុះមកត្រឹម ១៥៤នាក់ ក្នុង ១ សែនកំណើតរស់ដោយបន្តនិន្នាការវិជ្ជមាន នៃការថយចុះនូវមរណភាពមាតា ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ អត្រាមរណភាពទារក និងកុមារក៏ត្រូវបានគេមើលឃើញថាមានការធ្លាក់ចុះយ៉ាងខ្លាំងផងដែរ ដោយអត្រាមរណភាពទារកបានធ្លាក់ចុះពី ២៨នាក់ ក្នុង១,០០០កំណើតរស់ក្នុងឆ្នាំ២០១៤ មកត្រឹមតែ១២នាក់

[3] UNICEF, Cambodia Statistics.

[4] WHO, Cambodia Health Profile.

[5] World Bank, Cambodia Economic Growth.

[6] World Bank, Cambodia Healthcare Access.

[7] UNICEF, Cambodia Healthcare Expansion.

ក្នុង ១,០០០កំណើតរស់ ក្នុងឆ្នាំ ២០២១-២០២២[8] ។ ដូចគ្នានេះដែរ អត្រាមរណភាពកុមារក្រោម ៥ឆ្នាំ បានធ្លាក់ពី ៣៥ មក ១៦ ក្នុង ១,០០០កំណើតរស់ក្នុងរយៈពេលដូចគ្នានេះ[9]។ ទាក់ទងនឹងសុខភាពមាតា ការមានផ្ទៃពោះក្នុងវ័យជំទង់ត្រូវបានគេរាយការណ៍ថាមាន ៩% នៃស្ត្រីដែលមានអាយុពី១៥-១៩ឆ្នាំ ជាមួយនឹងប្រវ៉ាឡង់ខ្ពស់ នៅតាមតំបន់ជនបទ។ បន្ថែមពីលើនេះ ភាគរយ នៃស្ត្រីដែលមានអាយុពី១៥ ទៅ ៤៩ឆ្នាំដែលបានជួបប្រទះ ការបាត់បង់ផ្ទៃ បានធ្លាក់ពី ១២% ក្នុងឆ្នាំ២០១៤ មកត្រឹម ៩% ក្នុងឆ្នាំ២០២១-២០២២។ ការអង្កេតក៏បានរំលេចផងដែរ ថាមានការរំលូត/រលូត ចំនួន៤ ករណីក្នុងចំណោមស្ត្រី ១,០០០នាក់[10]។

ការទទួលបានសេវាពិនិត្យផ្ទៃពោះ (ANC) មានភាពប្រសើរឡើងយ៉ាងខ្លាំង ជាមួយអត្រាស្ត្រី ៩៩% ទទួលបានការថែទាំពីអ្នកផ្តល់សេវាមានជំនាញយ៉ាងហោចណាស់ម្តងក្នុងអំឡុងពេលមានផ្ទៃពោះចុងក្រោយរបស់ពួកគាត់។ ភាគរយ នៃស្ត្រីដែលចូលរួមពិនិត្យផ្ទៃពោះ បួនដង ឬច្រើនជាងក៏បានកើនឡើងទៅដល់ ៨៦% គឺបង្ហាញពីការប្រើប្រាស់សេវាសុខភាពមាតាកាន់តែប្រសើរឡើង។ ជារួមសូចនាករទាំងនេះឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងប្រកបដោយជោគជ័យរបស់កម្ពុជាក្នុងការបង្កើនការទទួលបានសេវាថែទាំសុខភាព និងគុណភាពកាន់តែប្រសើររួមចំណែកដល់លទ្ធផលសុខភាពកាន់តែប្រសើរឡើងសម្រាប់ម្តាយ និងកុមារ នៅទូទាំងប្រទេស។

អាហារូបត្ថម្ភ និងការទទួលបានទឹកស្អាត

ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា (CDHS) ឆ្នាំ២០២១-២០២២ ក៏ផ្តល់នូវការមើលឃើញសំខាន់ៗអំពីស្ថានភាពអាហារូបត្ថម្ភរបស់កុមារអាយុក្រោម៥ឆ្នាំ និងស្ថានភាពទឹក និងអនាម័យក្នុងគ្រួសារនៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។ **ស្ថានភាពអាហារូបត្ថម្ភ៖** ការអង្កេតបានរំលេចថា ២២% នៃកុមារអាយុក្រោម៥ឆ្នាំមានការក្រិនដែលបង្ហាញពីភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ចេញពី ៣២% ក្នុងឆ្នាំ២០១៤។ ទោះជាយ៉ាងណាក៏ដោយកង្វះអាហារូបត្ថម្ភនៅតែជាកង្វល់មួយដោយសារមានកុមារ ១៦% ទម្ងន់ទាប ១០% ស្គមស្គាំង និង៤% លើសទម្ងន់។ ជាការកត់សម្គាល់ ការក្រិនមានច្រើននៅតំបន់ជនបទ ក្នុងអត្រា ២៤.៧% ធៀបនឹង ១៦.៨% នៅក្នុងតំបន់ទីក្រុង។ ភាពខុសគ្នានេះគួសបញ្ជាក់បញ្ហាប្រឈមកំពុងកើតមានលើសុខភាព និងអាហារូបត្ថម្ភនៅទីជនបទ បើទោះបីមានភាពប្រសើរឡើងជាទូទៅខាងស្ថានភាពអាហារូបត្ថម្ភរបស់កុមារ នៅទូទាំងប្រទេសក៏ដោយ។ **ទឹកស្អាត និង អនាម័យក្នុងគ្រួសារ៖** ការអង្កេតក៏បង្ហាញពីវឌ្ឍនភាពក្នុងការទទួលបានទឹកស្អាតកម្រិតចាំបាច់ដោយប្រជាជន ៨៩% ទទួលបានទឹកស្អាតប្រើក្នុងរដូវប្រាំង និង៩២%នៅរដូវវស្សា។ ទោះជាយ៉ាងណាក៏ដោយប្រជាជនមួយចំនួនតូចប្រហែល ២% ក្នុងរដូវប្រាំង និង១% ក្នុងរដូវវស្សានៅតែប្រឈមមុខនឹងការទទួលបានទឹកស្អាតប្រើប្រាស់។ ភាពអាចទទួលបានទឹកស្អាតគ្រប់គ្រាន់មានកម្រិតខ្ពស់ទាំងនៅជនបទ និងទីក្រុង ដោយមាន ៨៩% នៃគ្រួសាររាយការណ៍ថាមានទឹកគ្រប់គ្រាន់នៅពេលត្រូវការ។ លើសពីនេះទៀត មាន៦៨% នៃប្រជាជនរស់នៅក្នុងគ្រួសារដែលប្រើវិធីសម្អាតទឹកសមស្រប ដោយនៅតំបន់ទីក្រុងមានកម្រិតប្រសើរជាងនៅតំបន់ជនបទ។ ទិន្នន័យនេះឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការកែលម្អសេវាទឹក និងសេវាអនាម័យ ដែលមានសារៈសំខាន់សម្រាប់សុខភាពសាធារណៈ និងសុខុមាលភាព នៅកម្ពុជា។ របកគំហើញទាំងនេះបានគូសបញ្ជាក់ការប្រឹងប្រែងយ៉ាងខ្លាំងដែលកម្ពុជាបានធ្វើក្នុងការធ្វើឱ្យប្រសើរឡើងផ្នែកអាហារូបត្ថម្ភ និងការទទួលបានទឹកស្អាត និងអនាម័យ ទន្ទឹមគ្នានេះក៏រំលេចផងដែរអំពីតំបន់នានាដែលត្រូវការកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ជាពិសេសនៅក្នុងសហគមន៍ជនបទ។

[8] UNICEF, Cambodia Infant Mortality Rate.

[9] UNICEF, Cambodia Under-5 Mortality Rate.

[10] WHO, Cambodia Maternal Mortality Rate.

កំណើនសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជាមានកំណើនជាមធ្យម ៧.០% ក្នុងមួយឆ្នាំក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ[11]។ កំណើនសេដ្ឋកិច្ចនេះបាននាំឱ្យមានការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ជីវភាពស្តង់ដាសម្រាប់ប្រជាជនកម្ពុជាជាច្រើន[12]។ ក្នុងឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជាមានកំណើន ៥.២% ដែលស្ទុះងើបឡើងវិញពីផលប៉ះពាល់ នៃជំងឺរាតត្បាតកូវីដ-១៩។ ការងើបឡើងវិញនេះត្រូវបានជំរុញជាចម្បងដោយមានសកម្មភាពសេដ្ឋកិច្ចឡើងវិញ ជាពិសេសនៅក្នុងវិស័យផលិតកម្មសំណង់ និងសេវាកម្ម។ វិស័យកសិកម្ម ក៏បានរួមចំណែកជាវិជ្ជមានដល់កំណើនសេដ្ឋកិច្ចផងដែរ បើទោះបីក្នុងកម្រិតទាបជាងក៏ដោយ។ ជារួមការរីកចម្រើនលើស្ថានភាពសុខភាពទូទៅ និងការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជាបានបង្ហាញនូវការប្រសើរឡើងជាច្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ។ ក្នុងខណៈដែលប្រទេសនេះនៅតែប្រឈមមុខនឹងបញ្ហាប្រឈមនានា ការរីកចម្រើននេះស្ថិតនៅលើមាគ៌ាទៅកាន់ជាតិមួយប្រកបដោយសុខភាពល្អជាង និងចម្រុងចម្រើនជាង។

ខណៈដែលកម្ពុជាមានការរីកចម្រើនក្នុងការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសុខភាពគឺគួរឱ្យកោតសរសើរបែបនេះ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការទទួលស្គាល់ការនូវកំណើន នៃការគំរាមកំហែងកាន់តែខ្លាំងឡើងនៃភាព សាំនឹងឱសថប្រឆាំងមេរោគ នៅក្នុងប្រទេស។ ការប្រើប្រាស់មិនសមស្រប និងការប្រើប្រាស់លើសកម្រិតនូវឱសថអង់ទីប៊ីយ៉ូទិក ជាពិសេសឱសថសម្រាប់ មនុស្ស និងសត្វ គឺជាកត្តាចម្បងដែលបណ្តាលឱ្យមានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់ប្រទេសកម្ពុជាបាននាំឱ្យមានកំណើនតម្រូវការសម្រាប់ថ្នាំអង់ទីប៊ីយ៉ូទិក ដែលរួមចំណែកដល់ការឡើងខ្ពស់ នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ។ លើសពីនេះ កត្តានានាដូចជាការបង្ការ និងត្រួតពិនិត្យការចម្លងរោគមិនបានល្អ និងការប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិកក្នុងវិស័យកសិកម្មសត្វ ធ្វើឱ្យបញ្ហាកាន់តែធ្ងន់ធ្ងរឡើង[13]។

ផលវិបាក នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគប៉ះពាល់ ហើយអាចជះឥទ្ធិពលយ៉ាងសំខាន់ដល់ការអភិវឌ្ឍរបស់កម្ពុជា។ ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ អាចនាំឱ្យឈឺកាន់តែយូរចំណាយកាន់តែខ្ពស់ និងស្លាប់កាន់តែកើនឡើង។ ផលវិបាកទាំងនេះក៏អាចរារាំងការអភិវឌ្ឍសេដ្ឋកិច្ចដោយកាត់បន្ថយផលិតភាព និងការបង្កើនថ្លៃដើមនៃការធ្វើអាជីវកម្ម[14]។

ស្ថានភាពបច្ចុប្បន្ន នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅកម្ពុជា

ក្រុមការងារបច្ចេកទេសទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅកម្ពុជា បានធ្វើការពិនិត្យឡើងវិញយ៉ាងល្អិតល្អន់ នៅក្នុងឆ្នាំ ២០១៩[15] ដើម្បីស្វែងយល់ពីស្ថានភាពបច្ចុប្បន្ន នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នៅកម្ពុជា។

ឯកសារបោះពុម្ពផ្សាយ ស្តីពីការពិនិត្យឡើងវិញជាប្រព័ន្ធផ្តោតលើទិន្នន័យភាពស៊ាំនឹងឱសថប្រឆាំងមេរោគដែលបានបានបោះពុម្ពផ្សាយលើការធ្វើតេស្តប្រសិទ្ធភាពឱសថអង់ទីប៊ីយ៉ូទិក (AST) ទៅលើមេរោគដែលបានកំណត់ដោយប្រព័ន្ធតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគជាសកល (GLASS)។ ការពិនិត្យមើលឡើងវិញនេះ រួមបញ្ចូលការវិភាគលើរបាយការណ៍ដែលបានផ្សព្វផ្សាយចំនួន ២៤ នៅចន្លោះឆ្នាំ២០០០ និង

[11] World Bank, Cambodia GDP Growth.

[12] World Bank, Cambodia Poverty Reduction.

[13] Center for Disease Dynamics, Economics & Policy, Antimicrobial Resistance in Cambodia.

[14] World Economic Forum, The Global Risks Report 2023

[15] Antimicrobial resistance in Cambodia: a review DOI:https://doi.org/10.2026/j.ijid.2019.05.036

២០១៨ ដែលភាគច្រើនបង្ហាញពីបាក់តេរី (isolates) យកចេញពីអ្នកជំងឺ។ របកគំហើញបានបង្ហាញពីអត្រាភាពស៊ាំគួរឱ្យព្រួយបារម្ភនៅលើគ្រប់ភ្នាក់ងារបង្កជំងឺសំខាន់ៗជាច្រើន។

កម្រិតខ្ពស់ នៃភាពស៊ាំត្រូវបានកត់សម្គាល់នៅក្នុងមេរោគ *E. coli* ទៅនឹងឱសថអង់ទីប៊ីយ៉ូទិកដូចជា ampicillin, cephalosporins ជំនាន់ទី៣ fluoroquinolones និង gentamicin ។ ក្នុងករណី *K. pneumoniae* និង *S.-aureus* មានភាពស៊ាំគួរឱ្យកត់សំគាល់ជាមួយឱសថ fluoroquinolones, co-trimoxazole និង gentamicin ។ លើសពីនេះទៀត មេរោគ *Acinetobacter baumannii* បានបង្ហាញពីភាពស៊ាំជាមួយឱសថ carbapenems, gentamicin និង amikacin ចំណែកឯ *Salmonella* spp. បានបង្ហាញភាពស៊ាំជាមួយឱសថ fluoroquinolone គួរឱ្យកត់សម្គាល់ ជាពិសេសនៅក្នុងប្រភេទ *Salmonella Typhi*។

ការពិនិត្យឡើងវិញក៏បានបង្ហាញមេរោគ *Shigella* spp. និង *Neisseria gonorrhoeae*, *Shigella* spp. មិនបានបង្ហាញភាពស៊ាំជាមួយឱសថ ciprofloxacin ឬ azithromycin ទេ ផ្ទុយទៅនឹង *N. gonorrhoeae* បានបង្ហាញភាពស៊ាំខ្ពស់ជាមួយឱសថ ciprofloxacin និង penicillin ប៉ុន្តែមិនមែនចំពោះ cephalosporins ជំនាន់ទី៣ ទេ។ ទោះជាយ៉ាងណាក៏ដោយ ការបកស្រាយ នៃការរកឃើញទាំងនេះត្រូវបានរារាំងដោយចំនួន isolates មានកម្រិត និងអវត្តមាន នៃមេតាទិន្នន័យ (Metadata) នៃចំណាត់ថ្នាក់លម្អិត ដោយរំលេចតម្រូវការសម្រាប់ទិន្នន័យ រឹងមាំបន្ថែមទៀត ដើម្បីបង្កើតការយល់ដឹងពេញលេញ។

សរុបសេចក្តីមក ការពិនិត្យឡើងវិញដោយក្រុមការងារបច្ចេកទេសដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ បានកំណត់ពីការកើនឡើងយ៉ាងខ្លាំង នៃលទ្ធផលស្រាវជ្រាវទាក់ទងនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគពីព្រះរាជាណាចក្រកម្ពុជា ជាពិសេសក្រោយឆ្នាំ ២០១០។ ទោះបីជាមានវឌ្ឍនភាពយ៉ាងណាក៏ដោយ យើងនៅតែឃើញមានចំណុចខ្វះខាតសំខាន់ៗក្នុងទិន្នន័យ។ ការផ្តួចផ្តើមនៃប្រព័ន្ធតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគថ្នាក់ជាតិ ដែលស្របគ្នានឹងប្រព័ន្ធតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគជាសកល (GLASS) គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការបំពេញនូវចំណុចខ្វះខាតទាំងនោះ។ ប្រព័ន្ធទាំងនេះត្រូវបានរៀបចំឡើង ដើម្បីបង្កើនការយល់ដឹងរបស់យើងអំពីបែបផែន នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយផលប៉ះពាល់ នៃបញ្ហាប្រឈមសុខភាពសកលដែលកំពុងកើនឡើងនេះ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ក្រសួងសុខាភិបាលបានអនុម័ត និងដាក់ឱ្យដំណើរការប្រព័ន្ធតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគដែលមានមូលដ្ឋាននៅមន្ទីរពិសោធន៍។ ប្រព័ន្ធតាមដាននេះត្រូវបានបង្កើតឡើងនៅ ៨ទីតាំង រួមមាន ៣ទីតាំងនៅភ្នំពេញ និង៥ទីតាំងនៅតាមខេត្តផ្សេងៗ។ មន្ទីរពិសោធន៍ពាក់ព័ន្ធទាំងអស់ធ្វើតេស្តប្រសិទ្ធភាពឱសថប្រឆាំងមេរោគ (AST) និងការធានាគុណភាពពីខាងក្រៅ (EQA)។ វិទ្យាស្ថានជាតិសុខភាពសាធារណៈដើរតួជាមន្ទីរពិសោធន៍បង្អែកជាតិដែលទទួលការធានាគុណភាពខាងក្រៅពីមជ្ឈមណ្ឌលបណ្តុះបណ្តាលរោគសាស្ត្រប៉ាស៊ីហ្វិកនៅប្រទេសណូវែលហ្សេឡង់ (PPCT) និងកម្មវិធីធានាគុណភាពរបស់មហាវិទ្យាល័យរោគវិទ្យាវិទូអូស្ត្រាលី នៅប្រទេសអូស្ត្រាលី។ ប្រព័ន្ធតាមដាននេះ យោងទៅតាមប្រព័ន្ធតាមដាន GLASS ហើយផ្តោតលើភ្នាក់ងារបង្ករោគក្នុងអាទិភាពចំនួន ៦ បានពីសំណាកវិភាគឈាម និងទឹកខួរឆ្អឹងខ្នង[16]។

16 Escherichia coli, Klebsiella pneumoniae, Acinetobacter spp, Staphylococcus aureus, Streptococcus pneumoniae and Salmonella spp. and another pathogen of importance in Cambodia: Bukholderia pseudomallei.

នៅក្នុងឆ្នាំ ២០២៤ ព្រឹត្តិបត្រអង្កេតតាមដានមួយត្រូវបានផ្សព្វផ្សាយដោយក្រសួងសុខាភិបាល ដើម្បីបញ្ជាក់ពីរការរកឃើញដំបូង នៃប្រព័ន្ធអង្កេតតាមដាន។ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ ទិន្នន័យត្រូវបានប្រមូលពីអ្នកជំងឺសម្រាកពេទ្យចំនួន ៦៩៧,៤២៩នាក់ ដែលត្រូវបានបញ្ចូលក្នុងទីតាំងតាមដានទាំង ៨កន្លែង ក្នុងកំឡុង ៤ឆ្នាំ។ ចំណុចគួរឱ្យកត់សម្គាល់មួយ នៃអ្នកជំងឺទាំងនេះ ជាមធ្យមមាន១៥.៦% បានទទួលការយកសំណាកឈាមសម្រាប់ការធ្វើតេស្តរកភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ការរកឃើញនេះបង្ហាញពីអត្រាវិជ្ជមានប្រមាណ ១០% សម្រាប់មេរោគដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងអំឡុងពេលតាមដាន ដែលបង្ហាញពីកម្រិតដ៏គួរឱ្យព្រួយបារម្ភ នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នៅក្នុងចំណោមប្រជាជននោះ។

ភាពប្រែប្រួល នៃការប្រមូលសំណាកឈាម និងអត្រាវិជ្ជមាន នៃមេរោគ ក្នុងទីតាំងតាមដានផ្សេងគ្នាគួរឱ្យសម្គាល់។ ឧទាហរណ៍ មន្ទីរពេទ្យកុមារអង្គរបានបង្ហាញពីអត្រាខ្ពស់ នៃការប្រមូលសំណាក (៧៣.២%) បើធៀបនឹងខេត្តកំពង់ចាម (៤.៨%)។ ស្រដៀងគ្នានេះដែរ អត្រាវិជ្ជមានមេរោគខ្ពស់គឺ នៅមន្ទីរពេទ្យកាល់ម៉ែត (ចាប់ពី ១៤.៤% ដល់ ១៨.0%) និងមន្ទីរពេទ្យខេត្តសៀមរាប (៨.៩% ទៅ ១១.0%) បើធៀបនឹងទីតាំងតាមដានផ្សេងទៀត។ ភាពខុសគ្នានេះបញ្ជាក់ពីការអនុវត្តការថែទាំសុខភាព និងប្រវ៉ាឡង់ នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគមិនដូចគ្នា នៅតាមទីតាំងតាមដាននានា ដែលណែនាំឱ្យប្រើប្រាស់វិធានការច្បាស់លាស់សម្រាប់ការគ្រប់គ្រងភាពស៊ាំនឹងឱសថប្រឆាំងមេរោគឱ្យកាន់តែមានប្រសិទ្ធភាព។

លទ្ធផល នៃការអង្កេតតាមដានបានផ្តល់នូវការយល់ដឹងលម្អិតអំពីរបាយ នៃភ្នាក់ងារបង្កជំងឺផ្សេងៗ និងលំនាំ នៃភាពស៊ាំរបស់មេរោគទាំងនោះ។ គួរកត់សម្គាល់ថាមេរោគ *E. coli* និង *K. pneumoniae* គឺជាភ្នាក់ងារបង្ករោគដែលត្រូវបានរកឃើញញឹកញាប់បំផុត។ ទិន្នន័យនេះក៏បានចង្អុលបង្ហាញពីភាពស៊ាំខ្លាំងទៅលើឱសថអង់ទីប៊ីយ៉ូទិកប្រភេទ 'Access' និងប្រភេទ 'Watch' ។ ការវិភាគប្រជាសាស្ត្របានបង្ហាញថា ភ្នាក់ងារបង្ករោគមួយចំនួន គឺពាក់ព័ន្ធជាមួយអាយុ និងភេទរបស់អ្នកជំងឺ។ ឧទាហរណ៍ *Salmonella* spp. និង *Burkholderia pseudomallei* ត្រូវបានគេរកឃើញភាគច្រើន នៅលើមនុស្សពេញវ័យ ចន្លោះពី ១៥ ទៅ ៦៥ឆ្នាំ ចំណែក *K. pneumoniae* និង *Acinetobacter spp.* កើតមានច្រើនលើកុមារអាយុក្រោម ១ឆ្នាំ។

ការប្រើប្រាស់ថ្នាំប្រឆាំងមេរោគលើសត្វ នៅកម្ពុជាមិនមានការគ្រប់គ្រងល្អទេ។ ទិន្នន័យនៅលើការប្រើប្រាស់ថឱសថប្រឆាំងមេរោគ បច្ចុប្បន្នអាចរកបានតែពីអ្នកនាំចូលអ្នកវេចខ្ចប់ថ្នាំពេទ្យសត្វ និងរោងម៉ាស៊ីនផលិតចំណីសត្វប៉ុណ្ណោះប៉ុន្តែមិនមែនមកពីអ្នកចែកចាយបន្ត ឬអ្នកប្រើប្រាស់ចុងក្រោយទេដូចជាកសិករជាដើម (Sar et al., 2021)។ ទោះបីមានបទប្បញ្ញត្តិច្រើនកំពុងត្រូវបានបង្កើត ដើម្បីកែលម្អការត្រួតពិនិត្យមើលក៏ដោយ ក៏នៅតែមានគម្លាតចំណេះដឹង និងការអនុវត្តមិនសមស្របក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ រួមមានកសិករ ចិញ្ចឹមជ្រូក និងបក្សី អ្នកវិជ្ជាជីវៈសុខាភិបាលបសុពេទ្យ និងអ្នកលក់រាយថ្នាំពេទ្យសត្វ (Chea et al., 2021, 2023; Heyman, 2020; Om & McLaws,2016; Ström et al. 2018)។ លើសពីនេះ ការអនុវត្តជីវសុវត្ថិភាពកសិដ្ឋាយៗមិនគ្រប់គ្រាន់ទេ ដែលរួមចំណែកដល់ការប្រើប្រាស់ឱសថប្រឆាំងមេរោគខុស (Chea et al., 2020)។

ការសិក្សាសាកល្បងនាពេលថ្មីៗនេះ អង្កេតលើកសិករចិញ្ចឹមត្រីចំនួន៨0នាក់ នៅក្នុង៤ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីវាយតម្លៃការយល់ដឹង និងការអនុវត្តរបស់ពួកគាត់ទាក់ទងនឹងការប្រើប្រាស់ឱសថប្រឆាំងមេរោគ។ លទ្ធផលបានបង្ហាញថាកសិករភាគច្រើនមានការយល់ដឹងតិចតួចអំពីអ្វីជាថ្នាំអង់ទីប៊ីយ៉ូទិក និងជាឱសថប្រឆាំងមេរោគ។ ពួកគាត់ជាច្រើននាក់អាចនឹកឃើញតែត្រឹមឈ្មោះថ្នាំអង់ទីប៊ីយ៉ូទិកដែលពួកគាត់ប្រើជាប្រចាំប៉ុន្តែពួកគាត់ខ្វះចំណេះដឹងកាន់តែស៊ីជម្រៅអំពីថ្នាំទាំងនេះ (GDAHP, 2024)។

ជាការគួរឱ្យព្រួយបារម្ភ អ្នកចិញ្ចឹមត្រីជាច្រើនមិនអនុវត្តតាមឈុត នៃការព្យាបាលដែលត្រូវបានណែនាំ នៅពេលប្រើឱសថអង់ទីប៊ីយ៉ូទិកទេ។ ផ្ទុយទៅវិញ ពួកគាត់ពឹងផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន ឬចំណេះដឹង មិនពេញលេញដោយមិនស្វែងរកការណែនាំពីអ្នកវិជ្ជាជីវៈសុខាភិបាលវារីសត្វឡើយ។ ការសិក្សាបានរកឃើញថា កសិករភាគច្រើនគ្រប់គ្រងដោយខ្លួនឯងនូវថ្នាំអង់ទីប៊ីយ៉ូទិក និងឱសថប្រឆាំងមេរោគ ដោយគ្មានវេជ្ជបញ្ជា ឬការណែនាំវិជ្ជាជីវៈណាមួយឡើយ (MAFF, ២០២៤)។

ផែនការជាតិត្រួតពិនិត្យសំណល់សម្រាប់ផលិតផលវារីវប្បកម្មនៅឆ្នាំ២០២០ បានរកឃើញសារធាតុ ៩៤.៥ µg/kg នៃជុកស៊ីគ្លីន ក្នុងសំណាកត្រីពស់ មួយក្នុងចំណោម ៥០សំណាក យកពីកសិដ្ឋានវារីវប្បកម្ម នៅទូទាំងប្រទេសកម្ពុជា។ កម្រិតនេះគឺខិតជិតដល់ដែនកំណត់សំណល់អតិបរមា(MRL) នៃ១០០µg/kg ដែលត្រូវបានអនុញ្ញាតនៅក្នុងសហភាពអឺរ៉ុប។ លើសពីនេះទៀត ការពិនិត្យនានាក្រោមគោលការណ៍ណែនាំការប្រតិបត្តិវារីវប្បកម្មល្អ (GAqP) បានបង្ហាញថា កសិដ្ឋានជាច្រើនត្រូវការធ្វើកែលម្អការអនុវត្តរបស់ពួកគាត់ដើម្បីបំពេញតាមស្តង់ដាសុវត្ថិភាពចំណីអាហារដែលត្រូវតែម្រូវ។ បញ្ហាប្រឈមមួយទៀតដែលបានកំណត់ គឺការខ្វះខាតចំណេះដឹងអំពីជំងឺត្រី ដែលនាំឱ្យមានការព្យាបាលមិនត្រឹមត្រូវ និងមិនចំចំណុច (GDAHP, 2024)។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា សត្វដែលត្រូវបានចិញ្ចឹមសម្រាប់មនុស្សបរិភោគ តែងតែត្រូវបានគេសម្លាប់ក្នុងលក្ខខណ្ឌសាមញ្ញបែបប្រពៃណី និងគ្មានអនាម័យ។ ការអនុវត្តនេះអាចនាំឱ្យមានការចម្លងរោគ នៃផលិតផលសត្វដោយបាក់តេរី រួមមានអ្វីដែលបណ្តាលឱ្យរាគរូសផងដែរ។ ការរីករាលដាល នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ត្រូវបានគេរកឃើញក្នុងប្រភេទបាក់តេរីជាច្រើនដែលត្រូវបានរកឃើញនៅក្នុងសាកសពក្នុងអំឡុងពេលធ្វើរោងសត្វ សម្លាប់សត្វ និងដំណើរការទិញលក់។ បាក់តេរីមួយចំនួនដែលត្រូវបានកំណត់អត្តសញ្ញាណ រួមមាន Klebsiella pneumoniae, Escherichia coli, Staphylococcus aureus, Streptococcus suis, Campylobacter spp. Salmonella enterica serovar Typhi, Salmonella spp., Salmonella choleraesuis, Shigella spp., Pseudomonas aeruginosa, and Vibrio parahaemolyticus (CIRAD, 2024)។

ការសិក្សាថ្មីៗមួយ លើភាពស៊ាំនឹងឱសថប្រឆាំងមេរោគក្នុងសំណាកសត្វជ្រូក បង្ហាញពីភាពស៊ាំនឹងកម្រិតខ្ពស់ចំពោះ cefotaxime (២៥%) ភាពស៊ាំនឹងកម្រិតទាបចំពោះ ceftazidime (១០%) និងភាពស៊ាំកម្រិតខ្ពស់ចំពោះអាស៊ីត ciprofloxacin/nalidixic acid (៤២%ទាំង២មុខ)។ ឱសថប្រឆាំងមេរោគទាំងនេះត្រូវបានចាត់ថ្នាក់ដោយអង្គការសុខភាពពិភពលោកថាជា "ឱសថប្រឆាំងមេរោគសំខាន់ៗក្នុងអាទិភាពខ្ពស់បំផុត"។ លើសពីនេះ កម្រិតនៃភាពស៊ាំខ្ពស់ត្រូវបានគេរកឃើញសម្រាប់ ceftiofur (៣០%), cefotaxime (៣១%), ceftazidime (២៦%), enrofloxacin (៦៧%) និង ciprofloxacin (៨១%)។ ការសិក្សានេះក៏បានរកឃើញថា ៧៤% នៃសំណាកនៅក្នុងផ្នែកទី១ និង៩៥% នៅក្នុងផ្នែកទី២ បង្ហាញពីភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ បីថ្នាក់ ឬច្រើនថ្នាក់។ របកគំហើយទាំងនេះបង្ហាញពីការប្រើប្រាស់ឱសថប្រឆាំងមេរោគមិនត្រឹមត្រូវយ៉ាងទូលំទូលាយនៅក្នុងវិស័យចិញ្ចឹមជ្រូក ដោយបញ្ជាក់ពីតម្រូវការសម្រាប់ការពង្រឹងការគ្រប់គ្រងឱសថប្រឆាំងមេរោគ។ ទិន្នន័យនេះមានសារសំខាន់នៅពេលដែលកម្ពុជាបន្តកសាងសមត្ថភាពអង្កេតតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគរបស់ខ្លួននៅក្នុងផែនការសកម្មភាពជាតិ (GDAHP, 2022)។

លទ្ធផលមុនៗដែលបានមកពីការតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ សង្កត់ធ្ងន់លើបញ្ហាប្រឈមដែលកំពុងកើតមានក្នុងការប្រយុទ្ធប្រឆាំងនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅកម្ពុជា រួមទាំងតម្រូវការ

សម្រាប់ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពមន្ទីរពិសោធន៍ ពិធីសារព្យាបាលតាមស្តង់ដា និងយន្តការអង្កេតតាមដានត្រូវបានពង្រឹង។ ការគាំទ្រជាបន្តបន្ទាប់ពីស្ថាប័នរដ្ឋាភិបាល និងអន្តរជាតិ គឺជាការចាំបាច់ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ។ វាបានបង្ហាញពីសារៈសំខាន់ នៃយុទ្ធសាស្ត្ររួមបញ្ចូលមួយដែលពាក់ព័ន្ធនឹងស្ថាប័នផ្តល់សេវាថែទាំសុខភាពអ្នកធ្វើគោលនយោបាយ និងសហគមន៍ទាំងមូល។

ទិដ្ឋភាពទូទៅ (២០១៣-២០១៨)

ដំណើររបស់កម្ពុជាក្នុងការដោះស្រាយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ត្រូវបានគូសបញ្ជាក់ដោយការអភិវឌ្ឍគោលនយោបាយសំខាន់ៗ និងគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រ ដោយចាក់ជាគ្រឹះមួយសម្រាប់កិច្ចខិតខំប្រឹងប្រែងជាប់ជាបន្តរបស់ព្រះរាជាណាចក្រកម្ពុជា ប្រឆាំងនឹងបញ្ហាប្រឈមសុខភាពជាសកល។ សសរគ្រឹះ នៃកិច្ចខិតខំប្រឹងប្រែងទាំងនេះគឺរបាយការណ៍វិភាគស្ថានភាពភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ក្នុងឆ្នាំ២០១៣ ដែលនាំទៅដល់ការបង្កើតគោលនយោបាយជាតិដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នៅក្នុងឆ្នាំ២០១៤ និងយុទ្ធសាស្ត្រជាតិដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ២០១៥-២០១៧ ។ ឯកសារសំខាន់ៗទាំងនេះត្រូវបានបង្កើតឡើងតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នាដែលពាក់ព័ន្ធនឹងនាយកដ្ឋានផ្សេងៗ នៃក្រសួងសុខាភិបាលមន្ទីរពេទ្យរដ្ឋ ឯកជន មន្ទីរពិសោធន៍ និងសង្គមវិជ្ជាជីវៈទាំងអស់នេះដើរតួសំខាន់នៅក្នុងការងារដែលទាក់ទងនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

គោលនយោបាយជាតិ និងយុទ្ធសាស្ត្រជាតិត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រប្រាំពីរចំណុចដែលត្រូវបានរៀបចំឡើងដើម្បីឱ្យត្រូវតាមតម្រូវការជាក់លាក់របស់កម្ពុជា ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧។ ផែនការយុទ្ធសាស្ត្រទាំងនោះរួមមាន ការបង្កើតផែនការជាតិគ្រប់ជ្រុងជ្រោយមួយ ការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ និងការអង្កេតតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ការធានាការទទួលបានឱសថប្រឆាំងមេរោគប្រកបដោយគុណភាព និយ័តកម្ម និងលើកកម្ពស់ការប្រើប្រាស់ឱសថសមស្រប ការលើកកម្ពស់ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ និងជំរុញការស្រាវជ្រាវ និងនវានុវត្តន៍។

ស្របទៅនឹងកិច្ចខិតខំប្រឹងប្រែងទាំងនេះនៅក្នុងវិស័យសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមការគាំទ្រពីអង្គការ FAO បានប្រមូលផ្តុំលើការរួមបញ្ចូលវិស័យម្ហូបអាហារ និងកសិកម្មទៅក្នុងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ក្នុងអំឡុងឆ្នាំ ២០១៦-២០១៧។ កិច្ចសហការនេះនាំឱ្យមានការវិវឌ្ឍនូវផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសុខភាពតែមួយ ដោយផ្តោតលើអាហារ និងកសិកម្មកាន់តែច្រើន។ ផែនទីបង្ហាញផ្លូវនេះបានគូសបញ្ជាក់ផែនការសកម្មភាពចំនួនប្រាំពីរ៖ យន្តការសម្របសម្រួលការចែករំលែកព័ត៌មាន និយ័តកម្ម ការអង្កេតតាមដានការស្រាវជ្រាវ និងការអនុវត្តមន្ទីរពិសោធន៍ការប្រើប្រាស់ឱសថសមស្រប និងការតស៊ូមតិ និងការយល់ដឹង។ ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដែលត្រូវបានផ្តួចផ្តើមឡើងក្នុងឆ្នាំ២០១៧ បានដាក់បញ្ចូលអង្គភាពជាច្រើន រួមមានអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (GDAHP) និងរដ្ឋបាលជលផល (FiA) ដែលត្រូវបានសម្របសម្រួលដោយក្រុមការងារបច្ចេកទេសភាពស៊ាំនឹងឱសថប្រឆាំងមេរោគរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានបង្កើតឡើងក្នុងខែតុលា ឆ្នាំ២០១៧ ជាមួយនឹងជំនួយបច្ចេកទេសពីអង្គការ FAO និងWOAH។

ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ២០១៩-២០២៣

ការបង្កើត និងការអនុម័តនូវផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ២០១៩-២០២៣ តំណាងឱ្យព្រឹត្តិការណ៍ដ៏សំខាន់មួយនៅក្នុងគោលនយោបាយសុខភាពសាធារណៈរបស់កម្ពុជា។ ផែនការនេះ ជាលើកដំបូង ក្នុងវិសាលភាពនៃវិធីសាស្ត្របែបសហការ បានដាក់ចេញជាមូលដ្ឋានគ្រឹះសម្រាប់យុទ្ធសាស្ត្រនាពេលខាងមុខសម្រាប់ឆ្នាំ២០២៤-២០២៨។ ផែនការសកម្មភាពឆ្នាំ២០១៩-២០២៣

ត្រូវបានគាំទ្រដោយការសន្យាមួយពីក្រសួងបី នៃប្រទេសកម្ពុជាក្នុងការធ្វើសមាហរណកម្មវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ ស្អិតរមួត និងស៊ីសង្វាក់គ្នាក្នុងការបង្ការ និងទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ក្រសួងទាំងបី បានប្តេជ្ញាចិត្តជំរុញសកម្មភាពនានាប្រកបដោយនិរន្តរភាព ប្រឆាំងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដែលពង្រឹងវឌ្ឍនភាពសេដ្ឋកិច្ចសង្គម និងរួមចំណែកដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ ការទទួលស្គាល់ថាភាពស៊ាំនឹងឱសថប្រឆាំងមេរោគបានផ្តើមចេញពីការប្រើប្រាស់មិនសមស្រប និងការប្រើប្រាស់ឱសថប្រឆាំងមេរោគលើសកម្រិតក្នុងវិស័យថែទាំសុខភាព កសិកម្ម និងឧស្សាហកម្មម្ហូបអាហារ ផែនការនេះបានទទួលស្គាល់ការរីកចម្រើនចាប់តាំងពីការបង្កើតនូវគោលនយោបាយជាតិឆ្នាំ២០១៤ និងយុទ្ធសាស្ត្រជាតិឆ្នាំ២០១៥-២០១៧ ប្រឆាំងនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ផែនការកន្លងមកនេះ គឺស្របគ្នាជាមួយគោលបំណងអភិវឌ្ឍរបស់ប្រទេសកម្ពុជា និងផែនការសកម្មភាពសកលស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ដោយបានកំណត់លើការប្រើប្រាស់ធនធានមនុស្ស និងធនធានសំខាន់ៗផ្សេងទៀតដើម្បីអភិវឌ្ឍ និងប្រតិបត្តិយុទ្ធសាស្ត្រ និងសកម្មភាពនានាក្នុងផែនការ។ ជាតុផ្សំសំខាន់មួយនៃការអនុវត្តគឺបង្កើតគណៈកម្មការពហុវិស័យមួយដែលផ្តោតលើការត្រួតពិនិត្យមើល និងតាមដានការវិឌ្ឍរបស់ផែនការដែលជាសក្ខីភាពមួយចំពោះកម្រិតដែលមិនធ្លាប់មានពីមុនមក នៃកិច្ចសហប្រតិបត្តិការអន្តរក្រសួង។

ក្រុមការងារបច្ចកទេស បានធ្វើការវិភាគស្ថានភាពគ្រប់ជ្រុងជ្រោយមួយដែលនាំឱ្យមានចំណុចផ្តោតជាយុទ្ធសាស្ត្រចំនួនប្រាំពីរត្រូវបានអនុម័តសម្រាប់សកម្មភាពដែលត្រូវបានផ្តោតការយកចិត្តទុកដាក់៖

១- ការកសាងសមត្ថភាពមនុស្សសម្រាប់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ
២- ទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ តាមរយៈការអនុវត្តល្អ
៣- ប្រមូលកស្តុតាងតាមរយៈការអង្កេតតាមដាន និងមន្ទីរពិសោធន៍
៤- អភិបាលកិច្ច និងការសម្របសម្រួលដើម្បីកាត់បន្ថយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ
៥- បង្កើនការយល់ដឹងដល់សាធារណៈជន
៦- ការប្រើប្រាស់ឱសថប្រឆាំងមេរោគឱ្យបានសមស្រប
៧- ការស្រាវជ្រាវ និងនវានុវត្តន៍ សម្រាប់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ

ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ឆ្នាំ២០១៩-២០២៣ បានបម្រើការជាឧបករណ៍បង្ហាញទិសសម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរបស់ខ្លួនក្នុងការកំណត់ផ្នែកអាទិភាពសម្រាប់ការងារប្រកបដោយកិច្ចសហការ។ វាសំដៅទៅរកភាគីពាក់ព័ន្ធជាច្រើន រួមមានមន្ត្រីរដ្ឋាភិបាល អ្នកបង្កើតគោលនយោបាយដ៏មានឥទ្ធិពលអ្នកស្រាវជ្រាវ អ្នកអប់រំ អ្នកសារព័ត៌មាន អង្គការវិជ្ជាជីវៈ អ្នកតស៊ូមតិសហគមន៍ និងសម្ព័ន្ធមិត្តអន្តរជាតិដែលទាំងអស់ធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហាប្រឈមនានារបស់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ទន្ទឹមនឹងការអភិវឌ្ឍ និងការអនុវត្តផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅកម្ពុជាបានទទួលការគាំទ្រយ៉ាងច្រើនពីមូលនិធិពហុដៃគូសម្រាប់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR-MPTF)[17]។ ការផ្តល់មូលនិធិនេះបានដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តជាក់ស្តែង នៃផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដោយដើរតួយ៉ាងមានប្រសិទ្ធភាពជាមធ្យោបាយ នៃការអនុវត្ត

[17] Cambodia-Enhancing Governance | MPTF Office: https://mptf.undp.org/project/00124430

ជាក់ស្តែងសម្រាប់ផែនការនេះ។

ជាមួយនឹងការផ្តល់មូលនិធិដែលបានកំណត់របស់ខ្លួន AMR-MPTF បានគាំទ្រសកម្មភាពស្នូលនានា ដែលបានរៀបរាប់នៅក្នុងផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ មូលនិធិនេះបានជួយសម្រួលដល់ការបង្កើតរចនាសម្ព័ន្ធអភិបាលកិច្ចចាំបាច់ និងយន្តការសម្របសម្រួលផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគបានប្រមើលឃើញ។ ឧទាហរណ៍៖ ការបង្កើតយន្តការជាតិសម្របសម្រួលភាពស៊ាំនឹងឱសថប្រឆាំងមេរោគ សុខភាពតែមួយក្រោមធ័ត្ររបស់ IMCC-OH គឺជាជំហានដ៏សំខាន់មួយដែលស្របតាមផែនការសកម្មភាពពហុវិស័យលើអភិបាលកិច្ច និងកិច្ចសហប្រតិបត្តិការអន្តរក្រសួង[18]។

ភាពស៊ីសង្វាក់គ្នារវាងផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងគម្រោង AMR-MPTF បង្ហាញឱ្យឃើញគោលបំណងសំខាន់របស់គម្រោង ដូចជាការគាំទ្រសម្រាប់ការគ្រប់គ្រងឱសថប្រឆាំងមេរោគ និងការបង្កើតគោលការណ៍ណែនាំ ស្តីពីការប្រើប្រាស់ និងការតាមដានបរិមាណឱសថប្រឆាំងមេរោគ។ គោលការណ៍ការណែនាំទាំងអស់នេះជាធាតុផ្សំសំខាន់ នៃក្របខ័ណ្ឌផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ជាងនេះទៅទៀត កិច្ចខិតខំប្រឹងប្រែងរបស់គម្រោង AMR-MPTF ក្នុងការលើកកម្ពស់ការយល់ដឹង និងការលើកកម្ពស់ការប្រើប្រាស់ឱសថប្រឆាំងមេរោគប្រកបដោយការទទួលខុសត្រូវលើវិស័យសុខភាពមនុស្ស សុខភាពសត្វ និងកសិកម្ម បានបំពេញបន្ថែមដោយផ្ទាល់នូវផែនយុទ្ធសាស្ត្ររបស់ MSAP។ សិក្ខាសាលាអប់រំវគ្គបណ្តុះបណ្តាល និងសម្ភារៈប្រាស្រ័យទាក់ទងដែលផ្តល់មូលនិធិ និងផ្សព្វផ្សាយដោយគម្រោង AMR-MPTF បានពង្រីកទៅដល់គោដៅ នៃគំនិតផ្តួចផ្តើមរបស់ MSAP។

បញ្ហាប្រឈមនានា ដូចជាលក្ខណៈស្មុគស្មាញ នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងធនធានមានកម្រិតត្រូវបានដោះស្រាយមួយផ្នែកតាមរយៈការដាក់ពង្រាយយុទ្ធសាស្ត្រ នៃធនធានរបស់គម្រោង MPTF ដោយធានាថាការប្រតិបត្តិផែនការសកម្មភាពពហុវិស័យអំពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ មិនជាប់គាំងទោះបីជាមានឧបសគ្គធនធានដែលអាចនឹងជួបក៏ដោយ។

[18] Antimicrobial Resistance Multi-Partner Trust Fund annual report 2021, UNDP.

ការវាយតម្លៃការអនុវត្តផែនការសកម្មភាពពហុវិស័យស្តីពីភាពសុំនឹងឱសថប្រឆាំងមេរោគ ឆ្នាំ ២០១៩-២០២៣

ការវាយតម្លៃរួមគ្នាពីខាងក្រៅរបស់និយ័តកម្មសុខភាពអន្តរជាតិ (IHR JEE) ២០២៤

ការវាយតម្លៃរួមគ្នាពីខាងក្រៅ (JEE) សម្រាប់កម្ពុជាបានវាយតម្លៃសមត្ថភាពរបស់ប្រទេសនេះ ក្នុងការគ្រប់គ្រងភាពសុំនឹងឱសថប្រឆាំងមេរោគ នៅក្រោមប្រភេទបង្គារ ដោយផ្តល់នូវការពិនិត្យឡើងវិញលម្អិត នៃសូចនាករពាក់ព័ន្ធជាច្រើន។ ការវាយតម្លៃបានផ្តល់លទ្ធផលចម្រុះដោយពិន្ទុដែលឆ្លុះបញ្ចាំងទាំងភាពខ្លាំង និងផ្នែកនានាដែលត្រូវការកែលម្អ។ ជាពិសេសពិន្ទុសម្រាប់ P.៤.១ ដល់ P.៤.៥ មានចន្លោះពី១ និង៤។ ពិន្ទុខ្ពស់បំផុត ៤ ត្រូវបានសម្រេចនៅក្នុង P.៤.២ ដែលបង្ហាញពីការតស៊ូមតិយ៉ាងខ្លាំងក្លា និងការធានានូវការផ្តល់មូលនិធិក្នុងស្រុកសម្រាប់ភាពសុំនឹងឱសថប្រឆាំងមេរោគ។ ហើយ នៅក្នុង P.៤.៣ ឆ្លុះបញ្ចាំងពីការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវវិធីសាស្ត្រសុខភាពតែមួយ ដើម្បីរៀបចំជាផ្លូវការនូវអភិបាលកិច្ច និងការអនុវត្តផែនការសកម្មភាពពហុវិស័យភាពសុំនឹងឱសថប្រឆាំងមេរោគ។

ដើម្បីដោះស្រាយគម្លាតដែលត្រូវបានរកឃើញ និងពង្រឹងបន្ថែមនូវការគ្រប់គ្រងភាពសុំនឹងឱសថប្រឆាំងមេរោគ ការវាយតម្លៃរួមគ្នាពីខាងក្រៅបានផ្តល់អនុសាសន៍ឱ្យធ្វើសកម្មភាពជាច្រើន៖

ការតស៊ូមតិ និងការផ្តល់មូលនិធិ៖ បន្តការតស៊ូមតិសម្រាប់ភាពសុំនឹងឱសថប្រឆាំងមេរោគ និងធានាផ្តល់មូលនិធិក្នុងស្រុកសម្រាប់ភាពសុំនឹងឱសថប្រឆាំងមេរោគ ដោយធ្វើការជាមួយដៃគូអភិវឌ្ឍន៍ និងយន្តការកៀរគរធនធានដែលត្រូវបានបង្កើតឡើង។

វិធីសាស្ត្រសុខភាពតែមួយ៖ ប្រើប្រាស់វិធីសាស្ត្រសុខភាពតែមួយនេះ ដើម្បីរៀបចំជាផ្លូវការនូវអភិបាលកិច្ច និងការអនុវត្តផែនការសកម្មភាពជាតិពហុវិស័យភាពសុំនឹងឱសថប្រឆាំងមេរោគ និងធានាចែករំលែកទិន្នន័យពាក់ព័ន្ធ។

ការធ្វើបច្ចុប្បន្នភាព SOP៖ ធ្វើបច្ចុប្បន្នភាពនីតិវិធីប្រតិបត្តិការស្តង់ដា (SOPs) ដើម្បីកំណត់អត្តសញ្ញាណមេរោគ អាទិភាពដែលធន់នឹងឱសថច្រើនប្រភេទ (MDRO) ក្នុងវិស័យមនុស្ស និងសត្វ។

ការអនុវត្តប្រសើរបំផុត៖ លើកកម្ពស់ការអនុវត្តល្អបំផុតនៅកម្រិតស្ថាប័នក្នុងការអនុវត្តទិន្នន័យភាពសុំនឹងឱសថប្រឆាំងមេរោគ ទៅក្នុងការអនុវត្តគ្លីនិក និងអង្កេតការបង្ការនិងការត្រួតពិនិត្យការចម្លងរោគ។

ការតាមដាន៖ ពង្រីកការតាមដានភាពសុំនឹងឱសថប្រឆាំងមេរោគ ក្នុងវិស័យសត្វទៅកម្រិតថ្នាក់ក្រោមជាតិ និងចុះពិនិត្យបែបគាំទ្រជាប់ជាប្រចាំទៅទីតាំងតាមដាន។ សម្រាប់វិស័យមនុស្សការពង្រីកប្រព័ន្ធតាមដានសហគមន៍លើភាពសុំនឹងឱសថប្រឆាំងមេរោគ គឺជាការចាំបាច់។

ផែនការសកម្មភាពពហុវិស័យស្តីពីភាពសុំនឹងឱសថប្រឆាំងមេរោគ កំពុងតែអនុវត្តយ៉ាងសកម្មនូវអនុសាសន៍ដែលបានដាក់ចេញដោយការវាយតម្លៃរួមគ្នាពីខាងក្រៅក្នុងខែឧសភា ឆ្នាំ២០២៤។ តាមរយៈការធ្វើដូច្នេះ កម្ពុជាមានទិសដៅបង្កើនសមត្ថភាពជាតិរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងនឹងភាពសុំនឹងឱសថប្រឆាំងមេរោគប្រកបដោយប្រសិទ្ធភាពដោយធានាឱ្យមានការឆ្លើយតបប្រកបដោយការសម្របសម្រួល និងគ្រប់ជ្រុងជ្រោយនៅគ្រប់វិស័យពាក់ព័ន្ធ។

ការពិនិត្យតាមដានកម្រិតខ្ពស់ តាមរយៈ TrACSS

ការអង្កេតស្វ័យវាយតម្លៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគត្រីភាគីក្នុងប្រទេស (TrACSS) ដើរតួជាស្តង់ដាក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃកម្រិតខ្ពស់ (M&E Framework) សម្រាប់ផែនការសកម្មភាពជាតិ (NAPs) ដែលកំពុងដោះស្រាយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ការវាយតម្លៃប្រចាំឆ្នាំនេះ ចូលរួមដោយ FAO, WOAH, WHO, និងUNEP ប្រមូលទិន្នន័យនៅទូទាំងវិស័យផ្សេងៗ រួមទាំងសុខភាពមនុស្ស កសិកម្ម សត្វ និងបរិស្ថាន[19]។

TrACSS ស្វែងយល់គ្រប់ជ្រុងជ្រោយមិនដូចវិធីសាស្ត្រពិនិត្យតាមដាន និងវាយតម្លៃដែលធ្លាប់ធ្វើនាពេលកន្លងមកដែលជារឿយៗធ្វើតែលើវិស័យជាក់លាក់ណាមួយ។ TrACSS ប្រើប្រាស់កម្រងសំណួរស្តង់ដា និងគំរូស្តង់ដា ដើម្បីវាយតម្លៃវឌ្ឍនភាពរបស់ប្រទេសនានាក្នុងការអនុវត្តផែនការសកម្មភាពជាតិរបស់ពួកគេ។ TrACSS អនុញ្ញាតឱ្យមានការប្រៀបធៀបដោយផ្ទាល់រវាងប្រទេសនានា និងការកំណត់រកភាពខ្លាំង និងខ្សោយនៅទូទាំងផ្នែកផ្សេងៗ ដូចជាការអភិវឌ្ឍគោលនយោបាយ ប្រព័ន្ធអង្កេតតាមដាន និងការអនុវត្តការប្រើប្រាស់ឱសថប្រឆាំងមេរោគ។

គោលនយោបាយ និងការសម្របសម្រួល៖
កម្ពុជាបានបង្កើតអង្គភាព AMR និងគណៈកម្មការអន្តរក្រសួងសម្រាប់សម្របសម្រួលសុខភាពតែមួយដោយបង្ហាញការប្តេជ្ញាចិត្តមួយក្នុងការដោះស្រាយបញ្ហាពីគ្រប់ផ្នែក

ការអង្កេតតាមដាន៖
កិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងប្រព័ន្ធអង្កេតតាមដានសម្រាប់សុខភាពមនុស្ស និងសត្វកំពុងដំណើរការសំដៅប្រមូលទិន្នន័យសំខាន់ៗ លើទំនោរ AMR

ការប្រើប្រាស់ឱសថប្រឆាំងមេរោគ៖
គំនិតផ្តួចផ្តើមលើកកម្ពស់ការប្រើប្រាស់ឱសថប្រឆាំងមេរោគដោយប្រុងប្រយ័ត្នលើការថែទាំសុខភាពមនុស្ស និងសត្វកំពុងត្រូវបានពង្រីកជាជំហានដ៏សំខាន់មួយក្នុងការពន្យារពេល នៃការកើនឡើងរបស់ភាពស៊ាំ

ខណៈពេលដែល TrACSS ផ្តល់នូវការយល់ដឹងដ៏មានតម្លៃ វាបានទទួលស្គាល់ថាក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃក្នុងប្រទេសដែលមានលក្ខណៈលម្អិតជាង នៅតែមានសារៈសំខាន់។ លក្ខណៈស្តង់ដា នៃ TrACSS មិនបានគ្របដណ្តប់លើបរិបទ និងចំណុចលម្អិតមួយចំនួន ដែលអាចមើលរំលងភាពខុសប្លែកគ្នា និងបញ្ហាប្រឈមនានារបស់ប្រទេសជាក់លាក់ណាមួយ។ ដូច្នេះហើយ TrACSS ដំណើរការបានល្អបំផុតជាត្រីវិស័យកម្រិតខ្ពស់ ដែលចង្អុលប្រាប់ប្រទេសនានាទៅរកផ្នែកណាដែលត្រូវការ ការអង្កេតកាន់តែស៊ីជម្រៅ និងការអភិវឌ្ឍនូវផែនការពិនិត្យតាមដាន និងវាយតម្លៃតម្រូវនឹងបរិបទជាក់លាក់កាន់តែលម្អិតបន្ថែមទៀត។

TrACSS ផ្តល់នូវរូបភាពស្តង់ដាមួយ ដែលបង្ហាញអំពីចំណុចខ្លាំងគួរឱ្យកត់សម្គាល់ និងចំណុចខ្វះខាតដែលតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែម។ វាជាចំណុចចាប់ផ្តើមមិនទាន់ទៅដល់គោលដៅ ដែលត្រូវការត្រួសត្រាយផ្លូវបន្ថែមសមស្របសម្រាប់ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ដែលធានាបាននូវការពិនិត្យតាមដានគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាព សម្រាប់ការអនុវត្តផែនការសកម្មភាពជាតិ ជំរុញឱ្យមានវឌ្ឍនភាពក្នុងការប្រយុទ្ធនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ព្រះរាជាណាចក្រកម្ពុជាបានបុរេសកម្មចូលរួមនៅក្នុង TrACSS អស់រយៈពេលជាច្រើនឆ្នាំ[20] ដោយបញ្ជូនទិន្នន័យជាប់លាប់ និងរួមចំណែកទៅក្នុងចំណេះដឹងសកល។ ការចូលរួមយ៉ាងសកម្មនេះអនុញ្ញាតឱ្យមាន


[19] Global Database for Tracking Antimicrobial Resistance (AMR) Country Self- Assessment Survey (TrACSS).

[20] Tracking AMR Country Self-Assessment Survey (TrACSS) 2022 Country Report Cambodia.

ការវាយតម្លៃកម្រិតខ្ពស់ដំបូងលើការអនុវត្តផែនការសកម្មភាពជាតិ របស់កម្ពុជា។ លទ្ធផល នៃការវាយតម្លៃដំបូងស្នើឱ្យមានការវិឌ្ឍលើ៖

ទោះយ៉ាងណាក្តី បញ្ហាប្រឈមនៅតែមានជាពិសេសគឺចំណុចស្មុគស្មាញក្នុងការទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ មានផ្នែកមួយចំនួនត្រូវការ ការយកចិត្តទុកដាក់បន្ថែម រួមមាន៖

- សមត្ថភាពមន្ទីរពិសោធន៍៖ សម្រាប់វិស័យមនុស្ស និងសត្វ ការជានានូវហេដ្ឋារចនាសម្ព័ន្ធមន្ទីរពិសោធន៍ និងជំនាញគ្រប់គ្រាន់ គឺចាំបាច់សម្រាប់ការធ្វើរោគវិនិច្ឆ័យត្រឹមត្រូវ និងការតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ទោះជាយ៉ាងណាក៏ដោយ វិស័យបរិស្ថានចាំបាច់ត្រូវបង្កើត និង ឬ ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ ដើម្បីចូលរួមយ៉ាងពេញលេញក្នុងការអង្កេតតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។
- ការយល់ដឹងជាសាធារណៈ៖ ការអប់រំសាធារណៈជនអំពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងការប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិកប្រកបដោយទំនួលខុសត្រូវ គឺមានសារៈសំខាន់សម្រាប់ភាពជោគជ័យរយៈពេលវែង។
- ការវិភាគ និងការប្រើប្រាស់ទិន្នន័យ៖ ការបំប្លែងទិន្នន័យដែលប្រមូលបាន ប្រែទៅជាការយល់ដឹងដែលអាចអនុវត្តបាន ដើម្បីណែនាំអន្តរាគមន៍នាពេលអនាគត គឺជាគន្លឹះសំខាន់ ក្នុងការប្រយុទ្ធនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។



រូបភាពទី ១៖ របាយការណ៍ការតាមដានវាយតម្លៃដោយខ្លួនឯង នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគក្នុងប្រទេសកម្ពុជា (TrACSS) *ឆ្នាំ ២០២២៖ សុខភាពមនុស្ស*

ការវាយតម្លៃក្នុងការអនុវត្តការងាររបស់ប្រទេសកម្ពុជា ធៀបនឹងមធ្យមភាគសកលក្នុងឆ្នាំ២០២៣ បានគ្របដណ្តប់លើផ្នែកសុខភាពសាធារណៈសំខាន់ៗជាច្រើន៖

- ការបណ្តុះបណ្តាល និងការអប់រំអំពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ៖ ប្រទេសកម្ពុជាត្រូវបានដាក់ពិន្ទុ នៅ


កម្រិត C ដែលឆ្លុះបញ្ចាំងថាត្រូវបានអភិវឌ្ឍន៍។ នេះគឺស៊ីសង្វាក់នឹងមធ្យមភាគសកល ដែលត្រូវបានដាក់ទីតាំងនៅកម្រិត C ដែរ។

- ការពិនិត្យតាមដានបរិមាណឱសថប្រឆាំងមេរោគ៖ នៅទីនេះ ព្រះរាជាណាចក្រកម្ពុជាបានបង្ហាញពីសមត្ថភាពនៅមានកម្រិតទាបខ្លាំងណាស់ (A) ដែលស្ថិតនៅទាបជាងឆ្ងាយ ពីមធ្យមភាគក្នុងសកល (C)។
- ប្រព័ន្ធជាតិអង្កេតតាមដាន សម្រាប់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ៖ ប្រទេសកម្ពុជា បង្ហាញថានៅកម្រិតសមត្ថភាពខ្ពស់ (D) ដែលលើសពីមធ្យមភាគសកលដែលស្ថិតក្នុងនៅជំណាក់កាលត្រូវបានអភិវឌ្ឍន៍ (C)។
- ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ៖ កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាត្រូវគ្នា ជាមួយមធ្យមភាគសកល ទាំងពីរនេះត្រូវបានដាក់ពិន្ទុនៅជំណាក់កាលត្រូវបានអភិវឌ្ឍន៍ (C)។
- ការអនុម័ត នៃចំណាត់ថ្នាក់ AWaRe៖ ការឆ្លើយតបរបស់កម្ពុជាត្រូវបានវាយតម្លៃថា នៅកម្រិត C សម្រាប់សមត្ថភាពនៅមានកម្រិត ខណៈពេលដែលមធ្យមភាគសកលសម្រេចបាននូវស្ថានភាពត្រូវបាននូវអភិវឌ្ឍន៍ខ្ពស់ជាងគឺ (C)។

សរុបមក ការឆ្លើយតបរបស់កម្ពុជាក្នុងឆ្នាំ២០២៣ បានបង្ហាញឱ្យឃើញពីភាពស៊ីសង្វាក់គ្នាជាមួយនឹងមធ្យមភាគសកលទាក់ទងនឹងការបណ្តុះបណ្តាល និងការអប់រំស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ។ ប្រទេសកម្ពុជាបានបង្ហាញស្នាដៃខ្លាំង ក្នុងការអង្កេតតាមដានថ្នាក់ជាតិសម្រាប់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដែលបង្ហាញពីប្រព័ន្ធមួយរឹងមាំ និងមានប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយផ្នែកខ្លះ ដូចជាការត្រួតពិនិត្យបរិមាណឱសថប្រឆាំងមេរោគ និងការបញ្ចូលចំណាត់ថ្នាក់ AWaRe ទៅក្នុងបញ្ជីឱសថសារវន្តថ្នាក់ជាតិ (EML) បានបង្ហាញសក្តានុពលសម្រាប់ការកែចម្រើនដោយព្រះរាជាណាចក្រកម្ពុជានៅមានកម្រិតទាបជាងស្តង់ដាពិភពលោក។

ការវិភាគជាក់លាក់ដោយរបាយការណ៍ TrACSS៖ សុខភាពសត្វ

សូចនាករ TrACSS ក៏ផ្តល់នូវការវាយតម្លៃមួយ នៃវិធីសាស្ត្ររបស់កម្ពុជាក្នុងការគ្រប់គ្រងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នៅក្នុងវិស័យសុខភាពសត្វ ជាមួយនឹងការប្រៀបធៀបដោយផ្ទាល់ទៅនឹងមធ្យមភាគសកល។ ប្រព័ន្ធនេះចាត់ថ្នាក់សមត្ថភាពជាតិ និងភាពចម្រើន ដោយប្រើវិសាលគមមួយ ពី A តំណាងឱ្យ «គ្មានសមត្ថភាព» ទៅ E ដែលតំណាងឱ្យ «សមត្ថភាពត្រូវបានបំពាក់» ។




រូបភាពទី ២៖ របាយការណ៍ការតាមដានវាយតម្លៃដោយខ្លួនឯង នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគក្នុងប្រទេសកម្ពុជា (TrACSS) ឆ្នាំ ២០២២៖ សុខភាពសត្វ

ក្នុងការពិនិត្យឡើងវិញនូវទិន្នន័យឆ្នាំ២០២៣ កិច្ចខិតខំប្រឹងប្រែងរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ក្នុងវិស័យសុខភាពសត្វត្រូវបានវាស់វែងធៀបនឹងស្តង់ដាសកលលើសូចនាករផ្សេងៗ៖

- ការបណ្តុះបណ្តាល និងការអប់រំវិជ្ជាជីវៈអំពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ក្នុងវិស័យបសុពេទ្យ៖ ទាំងព្រះរាជាណាចក្រកម្ពុជា និងមធ្យមភាគសកលគឺស្ថិតនៅកម្រិត C ដែលបង្ហាញពីបញ្ហាប្រឈមរួមគ្នាក្នុងការលើកស្ទួយសមត្ថភាពនៅក្នុងផ្នែកដ៏សំខាន់នេះ។
- ការបណ្តុះបណ្តាល និងការអប់រំវិជ្ជាជីវៈអំពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ក្នុងវិស័យសុខភាពវារីសត្វ៖ ប្រហាក់ប្រហែលគ្នា កម្ពុជាឃើញខ្លួនឯងនៅកម្រិត B ស្របទៅនឹងមធ្យមភាគសកល ដោយចង្អុលតម្រូវការសកលសម្រាប់ក្របខ័ណ្ឌអប់រំដែលត្រូវបានធ្វើឱ្យប្រសើរឡើង។
- ប្រព័ន្ធតាមដានជាតិសម្រាប់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគសម្រាប់សត្វ៖ ប្រទេសកម្ពុជាបង្ហាញពីវឌ្ឍនភាពគួរឲ្យសរសើរដោយឈានដល់កម្រិត D សម្រាប់សមត្ថភាពដែលត្រូវបានបង្ហាញ ដែលឡើងផុតគួរឱ្យកត់សម្គាល់លើសពីមធ្យមភាគសកលដែលនៅកម្រិត C សម្រាប់សមត្ថភាពត្រូវបានអភិវឌ្ឍន៍។
- ប្រព័ន្ធជាតិអង្កេតតាមដាន សម្រាប់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគលើវារីសត្វ៖ ប្រទេសកម្ពុជាស្ថិតក្នុងកម្រិត A ដែលបង្ហាញពីតម្រូវការក្នុងការអភិវឌ្ឍសមត្ថភាពនៅក្នុងផ្នែកនេះ។
- សមាហរណកម្មប្រកបដោយប្រសិទ្ធភាព នៃមន្ទីរពិសោធន៍ ក្នុងការអង្កេតតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ៖ ការអង្កេតនេះត្រូវបានដាក់ចំណាត់ថ្នាក់នៅកម្រិត B ដែលបង្ហាញពីសមត្ថភាពនៅមានកម្រិត ក្នុងការរួមបញ្ចូលមន្ទីរពិសោធន៍ប្រកបដោយប្រសិទ្ធភាពសម្រាប់ការអង្កេតតាមដានភាពស៊ាំ

នឹងឱសថប្រឆាំងមេរោគ ដែលជាជំហានមួយ នៅពីក្រោយមធ្យមភាគសកលកម្រិតត្រូវបានអភិវឌ្ឍន៍កម្រិត C។

ការវិភាគបែបប្រៀបធៀបឆ្នាំ២០២៣ បង្ហាញថាយុទ្ធសាស្ត្រនានារបស់កម្ពុជាក្នុងវិស័យសុខភាពសត្វស្របទៅនឹងមធ្យមភាគសកលក្នុងផ្នែកនានា នៃបណ្តុះបណ្តាល និងការអប់រំវិជ្ជាជីវៈទាំងក្នុងវិស័យបសុពេទ្យ និងវារីវិស័យ។ ទោះជាយ៉ាងណាក៏ដោយវាជំណើរការលើសពីមធ្យមភាគសកលនៅក្នុងប្រព័ន្ធអង្កេតតាមដាន



រូបភាពទី ២៖ របាយការណ៍ការតាមដានវាយតម្លៃដោយខ្លួនឯង នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគក្នុងប្រទេសកម្ពុជា (TrACSS) *ឆ្នាំ ២០២២៖ អាហារ និងកសិកម្ម*

សម្រាប់សត្វ ដោយបង្ហាញពីវិធីសាស្ត្រជាតិដ៏រឹងមាំ។ ទោះជាយ៉ាងណាក៏ដោយមានគម្លាតគួរឱ្យកត់សម្គាល់ក្នុងសមាហរណកម្មមន្ទីរពិសោធន៍ប្រកបដោយប្រសិទ្ធភាពក្នុងការអង្កេតតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដែលជាចំណុចដែលកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាមិនទាន់ស្របតាមស្តង់ដាសកល។

ការវិភាគជាក់លាក់តាមវិស័យ៖ ម្ហូបអាហារ និងកសិកម្ម

ក្នុងការវាយតម្លៃវិធីសាស្ត្ររបស់កម្ពុជាចំពោះភាពស៊ាំនឹងឱសថប្រឆាំងមេរោគក្នុងវិស័យម្ហូបអាហារ និងកសិកម្ម យើងប្រើប្រាស់ទិន្នន័យ TrACSS ២០២៣ ដើម្បីប្រៀបធៀបសមត្ថភាព និងវឌ្ឍនភាពរបស់ប្រទេសធៀបនឹងមធ្យមភាគសកល។ TrACSS ដាក់ពិន្ទុផ្អែកលើមាត្រដ្ឋានមួយពី A ទៅ E ដែល A បង្ហាញពី «គ្មានសមត្ថភាព» និង E តំណាងឱ្យ «សមត្ថភាពត្រូវបានបំពាក់»។

សម្រាប់វិស័យម្ហូបអាហារ និងកសិកម្ម សូចនាករដែលត្រូវបានប្រើសម្រាប់វាយតម្លៃ រួមមាន៖

- ការបណ្តុះបណ្តាល និងការអប់រំវិជ្ជាជីវៈលើភាពស៊ាំនឹងឱសថប្រឆាំងមេរោគក្នុងវិស័យកសិកម្ម ចំណីអាហារ និងបរិស្ថាន៖ ព្រះរាជាណាចក្រកម្ពុជាត្រូវបានវាយតម្លៃនៅកម្រិត B ដែលបង្ហាញពីសមត្ថភាព

នៅមានកម្រិតដែលត្រូវសម្របតាមមធ្យមភាគសកល។

- សុវត្ថិភាពជីវសាស្ត្រ និងការអនុវត្តការចិញ្ចឹមសត្វល្អ ដើម្បីកាត់បន្ថយការប្រើប្រាស់ឱសថប្រឆាំងនឹងមេរោគ និង ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ក្នុងផលិតកម្មសត្វ៖ នៅកន្លែងនេះ ព្រះរាជាណាចក្រកម្ពុជាត្រូវបានគេវាយតម្លៃនៅកម្រិត B ដែលឆ្លុះបញ្ចាំងពីសមត្ថភាពនៅមានកម្រិត ដែលមធ្យមភាគសកលគឺស្ថិតក្នុងកម្រិតត្រូវបានអភិវឌ្ឍន៍ C។
- សុវត្ថិភាពជីវសាស្ត្រ និងការអនុវត្តការចិញ្ចឹមសត្វល្អ ដើម្បីកាត់បន្ថយការប្រើប្រាស់ថ្នាំប្រឆាំងមេរោគ និង ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ក្នុងផលិតកម្មវារីសត្វ៖ ប្រទេសកម្ពុជាស្ថិតនៅកម្រិត B ដែលបង្ហាញពីសមត្ថភាពនៅមានកម្រិតដោយមធ្យមភាគសកលឈរក្នុងកម្រិត B ជាកម្រិតទាបជាងស្តង់ដា។
- សមាហរណកម្មប្រកបដោយប្រសិទ្ធភាព នៃមន្ទីរពិសោធន៍ក្នុងការតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ក្នុងវិស័យសុខភាពសត្វ និងសុវត្ថិភាពចំណីអាហារ៖ ព្រះរាជាណាចក្រកម្ពុជាស្ថិតនៅកម្រិត B ដែលបង្ហាញពីសមត្ថភាពនៅមានកម្រិត។ នេះគឺទាបជាងមធ្យមភាគសកលបន្តិច ដែលស្ថិតនៅចន្លោះសមត្ថភាពនៅមានកម្រិត និងត្រូវបានអភិវឌ្ឍន៍ (B/C)។

ការវិភាគនេះបង្ហាញឱ្យឃើញថាប្រទេសកម្ពុជាគឺស្មើនឹងមធ្យមភាគសកលក្នុងវិស័យបណ្តុះបណ្តាល និងការអប់រំសម្រាប់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ក្នុងវិស័យកសិកម្ម ចំណីអាហារ និងបរិស្ថាន។ ទោះជាយ៉ាងណាក៏ដោយ ក៏បង្ហាញតម្រូវការសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវជីវសុវត្ថិភាព និងការអនុវត្តការចិញ្ចឹមសត្វល្អទាំងនៅក្នុងផលិតកម្មសត្វ និងវារីសត្វ ក៏ដូចជាសមាហរណកម្មមន្ទីរពិសោធន៍ក្នុងការអង្កេតតាមដានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ផ្នែកទាំងនេះបង្ហាញថា កម្ពុជាដើរតាមពីក្រោយមធ្យមភាគសកល។

សម្រាប់ប្រទេសកម្ពុជា ដើម្បីបង្កើនការឆ្លើយតបភាពស៊ាំនឹងឱសថប្រឆាំងមេរោគរបស់ខ្លួនក្នុងវិស័យម្ហូបអាហារ និងកសិកម្ម វិធីសាស្ត្រសំដៅទីមួយ គឺត្រូវការជាចាំបាច់ដើម្បីបង្កើនវិធានការជីវសុវត្ថិភាពការអនុវត្តការចិញ្ចឹម និងសមត្ថភាពមន្ទីរពិសោធន៍។ ការផ្តោតជាយុទ្ធសាស្ត្រនេះនឹងធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាស្របជាមួយស្តង់ដាសកលហើយអាចបង្កើតសំណាកសម្រាប់សម្រេចលើសស្តង់ដាសកលនាពេលអនាគត។

ការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ តាមរយៈក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ

ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ សម្រាប់ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ត្រូវបានបង្កើតឡើងតាមរយៈដំណើរការប្រឹក្សាយោបល់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធពីវិស័យសុខភាពមនុស្ស សុខភាពសត្វ កសិកម្ម និងវិស័យបរិស្ថាន។ ដោយឆ្លុះបញ្ចាំងពីវិធីសាស្ត្រសុខភាពតែមួយ ការអភិវឌ្ឍន៍ក្របខ័ណ្ឌត្រូវបានចង្អុលបង្ហាញដោយភាពដឹកនាំថ្នាក់ក្រសួង និងការចូលរួមយ៉ាងរាងវែពីអ្នកពាក់ព័ន្ធទាំងអស់។

ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃត្រូវបានគាំទ្រ ដោយកិច្ចសហការចតុភាគី WHO, FAO, WOAH និង UNEP និងសហហិរញ្ញប្បទានពីគម្រោង MPTF, AMR-TWG មកពី MoH, MAFF និង MoE ។ ការគាំទ្រ និងកិច្ចសហការទាំងនេះ មានសារៈសំខាន់យ៉ាងខ្លាំង។

បំណងនៅខាងក្រោយក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ គឺដើម្បីបង្កើតឧបករណ៍មុខងារមួយសម្រាប់ផលិតទិន្នន័យដើម្បីនាំផ្លូវក្នុងការអនុវត្ត និងការសម្រេចចិត្តយុទ្ធសាស្ត្រលើភាពស៊ាំនឹងឱសថប្រឆាំង

មេរោគក្នុងប្រទេសកម្ពុជា។ វាត្រូវបានរចនាឡើងដើម្បីគាំទ្រដល់ការអនុវត្តផែនការសកម្មភាពពហុវិស័យ បង្កើនគុណភាពទិន្នន័យ និងភាពអាចយកប្រើបានរួមបញ្ចូលគ្នានូវទិន្នន័យពីប្រភពផ្សេងៗ និងលើកកម្ពស់គណនេយ្យភាព។

ក្របខ័ណ្ឌនេះត្រូវបានរចនាឡើងជាពហុវិស័យ ដែលមានវិធីសាស្ត្រ និងសូចនាករដែលអាចប្រើបានចំពោះសុខភាពមនុស្ស សុខភាពសត្វ សុខភាពរុក្ខជាតិ និងសុខភាពបរិស្ថាន ជាមួយនឹងសកម្មភាពមួយចំនួនដែលត្រូវបានគ្រោង សម្រាប់សហប្រតិបត្តិ និងសម្រួលតម្រូវសម្រាប់វិស័យជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយក្របខ័ណ្ឌនេះទើបតែត្រូវបានបញ្ចប់នៅចុងឆ្នាំ២០២៣ ប៉ុណ្ណោះ។ ក្របខ័ណ្ឌនេះត្រូវបានកែសម្រួលនិងប្រើប្រាស់សម្រាប់ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ២០២៤-២០២៨។

ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃនេះ មានសមាសភាពត្រួតពិនិត្យ និងវាយតម្លៃពីរផ្នែក៖ ផ្នែកមួយផ្តោតលើដំណើរការ និងលទ្ធផលភ្លាមៗ ដើម្បីតាមដានភាពចម្រើនរបស់អ្នកពាក់ព័ន្ធ និងមួយទៀតវាយតម្លៃលទ្ធផលចុងក្រោយ និងគោលដៅនានា ដើម្បីវាយតម្លៃផលប៉ះពាល់ទៅលើនិន្នាការភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងបន្ទុកជំងឺ។

ជំពូកទី ២

គោលជៅ គោលបំណង និងឥតុបំណង

គោលដៅ គោលបំណង និងវត្ថុបំណង

ការកែសម្រួល នៃផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគរបស់កម្ពុជា គួសបញ្ជាក់ពីការប្តេជ្ញាចិត្តចំពោះការបង្កើតចក្ខុវិស័យ ដែលជាស្នូល នៃគោលដៅ វត្ថុបំណង និងគោលបំណងរបស់ផែនការដើមដោយមិនមានការផ្លាស់ប្តូរចំពោះដំណើរការទៅមុខ។ ផែនការដែលត្រូវបានធ្វើបច្ចុប្បន្នភាពនេះ បង្កើតឡើងដោយឈរលើមូលដ្ឋានដែលចង្អុលបង្ហាញយ៉ាងសម្រិតសម្រាំង ដើម្បីពង្រីកយុទ្ធសាស្ត្រ និងសកម្មភាពទាំងឡាយដែលត្រូវបានបង្កើតឡើងពីពេលមុន។

> **គោលដៅ**
>
> ផែនការសកម្មភាពពហុវិស័យ ប្រមើលឃើញថាប្រទេសមួយមានប្រជាជនមានសុខភាពល្អ និងប្រព័ន្ធអភិបាលកិច្ចរឹងមាំ ដោយធ្វើការសហការគ្នាដើម្បីបង្ការ និងគ្រប់គ្រងការគំរាមកំហែងពី *AMR* ដែលជាជំហានដ៏សំខាន់ឆ្ពោះទៅរកការសម្រេចបាននូវសន្តិសុខសុខភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលើវិស័យសុខភាពមនុស្ស សត្វ អាហារ និងបរិស្ថាន។

វត្ថុបណ្ឌះ៖

១. ការបង្កើតនូវក្របខ័ណ្ឌរួបរួមមួយ៖ ផែនការនេះបន្តផ្តួចផ្តើមហេដ្ឋារចនាសម្ព័ន្ធសហការ និងយន្តការនៃអភិបាលកិច្ចនានា ដែលផ្តល់សិទ្ធិអំណាចដល់ក្រសួង និងអ្នកពាក់ព័ន្ធ ដើម្បីធ្វើការរួមគ្នាទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

២. ការកំណត់ចំណុចខ្វះខាត និងកត្តាប្រឈម៖ វត្ថុបំណងដើម្បីបញ្ជាក់ និងដោះស្រាយបញ្ហាជាក់លាក់ដែលប៉ះពាល់ដល់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នៅតែជាអាទិភាពមួយដោយធានាថា ផែនការសកម្មភាពពហុវិស័យមានការឆ្លើយតប និងសម្របទៅនឹងទិដ្ឋភាពវិត្ត នៃការគំរាមកំហែងរបស់ឱសថប្រឆាំងមេរោគ។

៣. ការរៀបចំផែនការយុទ្ធសាស្ត្រ និងការសម្របសម្រួល៖ ផែនការដែលបានកែសម្រួលគឺដើម្បីកំណត់តំបន់យុទ្ធសាស្ត្រ វត្ថុបំណង និងសកម្មភាពច្បាស់លាស់ ដែលណែនាំអ្នកពាក់ព័ន្ធទាំងអស់តាមរយៈការធ្វើផែនការប្រចាំឆ្នាំ ការប្រាស្រ័យទាក់ទង និងការបែងចែកធនធាន។

គោលបំណង៖ ដើម្បីបង្ហាញ នៃការខិតខំប្រឹងប្រែងរួមគ្នារបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងដៃគូ និងអ្នកផ្តល់ជំនួយក្នុងការកំណត់ និងដោះស្រាយផ្នែកអាទិភាពសំខាន់ៗសម្រាប់ការបង្ការ និងទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ការណែនាំនេះសម្រាប់៖



យុទ្ធសាស្ត្រសកម្មភាព និងភារកិច្ចទាំងឡាយ ដែលត្រូវបានកំណត់នៅក្នុងផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាពីគ្រប់ភាគីពាក់ព័ន្ធ។ ភាគីពាក់ព័ន្ធនីមួយៗត្រូវបានលើកទឹកចិត្តឱ្យចូលរួមចំណែកក្នុងវិសាលភាព នៃជំនាញរបស់ពួកគាត់ដោយផ្អែកលើភារកិច្ច នៃអង្គភាពពួកគាត់។

ការកែសម្រួល នៃផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគនេះ មិនមែនជាការបង្កើតថ្មីឡើងវិញទេ ប៉ុន្តែជាការធ្វើឱ្យប្រសើរឡើង ដើម្បីធានាបាននូវភាពបន្តជាប់នឹងគោលដៅ គោលបំណង និងវត្ថុបំណងដែលត្រូវបានបង្កើតឡើង។ កិច្ចការនេះ តំណាងឱ្យការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នៃការរៀនសូត្រពីអតីតកាលដើម្បីជាព័ត៌មានសម្រាប់សកម្មភាពនាពេលអនាគត និងការសម្របខ្លួនទៅនឹងបញ្ហាប្រឈមថ្មីៗ ខណៈដែលប្រទេសជាតិខិតខំរក្សាជំហររបស់ខ្លួនក្នុងការប្រយុទ្ធជាសកលទៅនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ជំពូកទី ៣

ការបង្កើតផែនការ និងការចូលរួមរបស់តាគីពាក់ព័ន្ធ

ដំណើរការ នៃការធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ត្រូវបានផ្តួចផ្តើមឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០២៣ ក្រោមការដឹកនាំរបស់ MoH, MAFF និង MoE ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នានេះ មានគោលដៅដើម្បីកសាងនូវសមិទ្ធផលទាំងឡាយដែលបានចេញពីផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគដំណាក់កាលទីមួយក្នុងការដោះស្រាយបញ្ហា AMR តាមរយៈយុទ្ធសាស្ត្រថ្មី និងរួមបញ្ចូលគ្នាដោយមានការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗពីក្រសួងទាំងបី។

ដំណាក់កាលផ្តួចផ្តើមនៅខែកញ្ញា ឆ្នាំ២០២៣ បានចាប់ផ្តើមជាមួយនឹងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធយ៉ាងទូលំទូលាយដែលបានធ្វើឡើងដើម្បីវាយតម្លៃ និងទាញយកសមិទ្ធផល នៃផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគដំណាក់កាលទីមួយ។ ការវាយតម្លៃនេះមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងពីវឌ្ឍនភាពដែលត្រូវបានធ្វើឡើង និងកំណត់ចំណុចខ្វះខាតដែលផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគកំណែប្រែថ្មីត្រូវការដោះស្រាយ។ បន្ថែមពីលើការស្រាវជ្រាវ ការវិភាគលើព័ត៌មានដែលមានស្រាប់ យើងក៏បានពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ផងដែរ ដើម្បីឱ្យស្របទៅតាមផែនការថ្មីៗ ឬការណែនាំជាសកលដែលត្រូវបានកែសម្រួល។

នៅខែធ្នូ ឆ្នាំ២០២៣ សិក្ខាសាលាសម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗដំបូងត្រូវបានធ្វើឡើងនៅខេត្តកំពង់ចាម។ ដោយអ្នកចូលរួមត្រូវបានពិភាក្សាជាក្រុមលើសេចក្តីព្រាងដំបូង នៃផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ សិក្ខាសាលានេះបានជំរុញឱ្យមានការសហការមួយដើម្បីពិនិត្យឡើងវិញ និងចំណុចឯកភាពលើចក្ខុវិស័យ វត្ថុបំណង និងសកម្មភាពកម្រិតខ្ពស់ដោយដាក់ចេញនូវមូលដ្ឋានគ្រឹះនានា នៃផែនការសកម្មភាព។

បន្ទាប់ពីសិក្ខាសាលានេះ យើងបានបង្កើតសេចក្តីព្រាងដំបូងយ៉ាងទូលំទូលាយ នៃផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដែលត្រូវបានដាក់ជូនភាគីពាក់ព័ន្ធ ដើម្បីផ្តល់មតិយោបល់នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៤។ មតិកែលម្អដែលទទួលបានមានសារៈសំខាន់ក្នុងការបង្កើតផែនការដោយជានាថាវាឆ្លើយតបទៅនឹងតម្រូវការ និងការយល់ដឹង នៃភាគីពាក់ព័ន្ធទាំងអស់។ សិក្ខាសាលាបន្ទាប់មកទៀតបានធ្វើនៅខែមីនា ឆ្នាំ២០២៤ បានបើកឱកាសឱ្យភាគីពាក់ព័ន្ធស្វែងយល់ស៊ីជម្រៅទៅលើសកម្មភាពជាក់លាក់ និងថវិកាសម្រាប់សកម្មភាពនីមួយៗ ដោយធ្វើការលម្អិតបន្ថែមទៀតអំពីទិដ្ឋភាពប្រតិបត្តិការរបស់ផែនការ។

ខណៈដែលដំណាក់កាលនៃសេចក្តីព្រាងត្រូវបានបញ្ចប់ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ត្រូវបានសម្រិតសម្រាំងត្រូវបានដាក់ជូនភាគីពាក់ព័ន្ធសំខាន់ៗ សម្រាប់ជុំចុងក្រោយ នៃការប្រមូលធាតុចូល។ ជំហាននេះជានាថារាល់ទស្សនៈទាំងអស់ត្រូវបានយកមកពិចារណា និងបញ្ចូលទៅក្នុងឯកសារចុងក្រោយ ដែលត្រៀមរួចជាស្រេចសម្រាប់ការទទួលយក និងអនុវត្តយ៉ាងទូលំទូលាយ។ ដំណាក់កាលចុងក្រោយរួមបញ្ចូលក្រសួងទាំងបីឱ្យធ្វើការរួមគ្នាដើម្បីមានការយល់ដឹងនូវផែនការនេះក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗថ្នាក់ជាតិ និងស្វែងរកការយល់ព្រម នៅចុងឆ្នាំ ២០២៤។

ជំពូកទី ៤

យុទ្ធសាស្ត្រ ឥស្ថិបំណាច និងលទ្ធផលសំខាន់ៗ

យុទ្ធសាស្ត្រភស្តុបំណាច និងលទ្ធផលសំខាន់ៗ

ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅកម្ពុជា ឆ្នាំ២០១៩-២០២៣ បានកំណត់យុទ្ធសាស្ត្រចំនួនប្រាំពីរ៖

- អភិបាលកិច្ច និងការសម្របសម្រួលដើម្បីកាត់បន្ថយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ
- ប្រមូលភស្តុតាងតាមរយៈការអង្កេតតាមដាន និងមន្ទីរពិសោធន៍
- ការប្រើប្រាស់ឱសថប្រឆាំងមេរោគឱ្យបានសមស្រប
- ទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ តាមរយៈការអនុវត្តល្អៗ
- បង្កើនការយល់ដឹងជាសាធារណជន
- បង្កើនសមត្ថភាពធនធានមនុស្សសម្រាប់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ
- ស្រាវជ្រាវ និងនវានុវត្តន៍ដើម្បីប្រឆាំងនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ

សម្រាប់រយៈពេលឆ្នាំ ២០២៥-២០២៩ កម្ពុជាកំពុងរៀបចំឡើងវិញនូវផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដោយបង្រួបបង្រួមយុទ្ធសាស្ត្រទាំង៧ នេះទៅជាយុទ្ធសាស្ត្រ ៥ វិញ។ ការរៀបចំឡើងវិញនេះ ធ្វើឱ្យយុទ្ធសាស្ត្រភាពស៊ាំនឹងឱសថប្រឆាំងមេរោគរបស់កម្ពុជាស្របតាមផែនការសកម្មភាពសកល។

ដូចនេះផែនការសកម្មភាពពហុវិស័យ ស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ឆ្នាំ២០២៥-២០២៩ មានយុទ្ធសាស្ត្រ ៥ ដូចខាងក្រោម៖



វត្ថុបំណងស្នូល នៃយុទ្ធសាស្ត្រទាំង៥ ដំបូងនេះ គឺដើម្បីរក្សានូវសុច្ចរិតភាពរបស់វា បន្តការប្តេជ្ញាចិត្តចំពោះអភិបាលកិច្ចដ៏រឹងមាំ ការតាមដានប្រកបដោយប្រសិទ្ធភាពការប្រើប្រាស់ឱសថប្រឆាំងមេរោគឱ្យបានសមស្រប ការគ្រប់គ្រងការអនុវត្តល្អ និងការពង្រឹងការយល់ដឹងដល់សាធារណជន។ ទោះជាយ៉ាងណាក៏ដោយ ផែនការនេះរួមបញ្ចូលនូវធាតុសំខាន់ៗ នៃយុទ្ធសាស្ត្រ ២ចុងក្រោយទៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់នេះ៖

យុទ្ធសាស្ត្របង្កើនសមត្ថភាពធនធានមនុស្សដែលជាចំណុចផ្តោតលើយុទ្ធសាស្ត្រចាស់ទី៦ ឥឡូវនេះយុទ្ធសាស្ត្រនេះ ត្រូវបានបង្រៀតក្នុងគ្រប់យុទ្ធសាស្ត្រទាំង៥ ដោយធានានូវការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ នៃសមត្ថភាពសំខាន់ៗសម្រាប់គ្រប់ទិដ្ឋភាព នៃការឆ្លើយតបចំពោះភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

យុទ្ធសាស្ត្រស្រាវជ្រាវ និងនវានុវត្តន៍ ដែលពីមុននៅក្នុងយុទ្ធសាស្ត្រទី៧ ដាច់ដោយឡែកនោះ ឥឡូវនេះត្រូវបានបញ្ចូលក្នុងយុទ្ធសាស្ត្រទី២ ដើម្បីពង្រឹងប្រព័ន្ធតាមដាន ជាមួយនឹងការស្រាវជ្រាវដោយប្រើបច្ចេកវិទ្យាទំនើប និងដើម្បីបង្កើនសមត្ថភាពមន្ទីរពិសោធន៍ ដោយជំរុញឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីភាពស៊ាំនឹង

ឱសថប្រឆាំងមេរោគ។

សមាហរណកម្មនេះ ដើម្បីពង្រីកយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងការសម្របខ្លួនរបស់កម្ពុជា ដោយបន្ថែមការកសាងសមត្ថភាព និងការស្រាវជ្រាវលើគ្រប់គំនិតផ្តួចផ្តើមសម្រាប់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដើម្បីបង្កើតការឆ្លើយតបថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព និងបំពេញឱ្យគ្នា។

យុទ្ធសាស្ត្រទី ១៖ អភិបាលកិច្ច និងការសម្របសម្រួលដើម្បីកាត់បន្ថយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ

ស្ថានភាពបច្ចុប្បន្ន

រដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់សម្របសម្រួលសុខភាពតែមួយ (IMCC-OH) នៅក្នុងឆ្នាំ២០២៣។ គណៈកម្មការនេះមានការចូលរួមពីតំណាងមកពី ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធានាឱ្យមានការឆ្លើយតបជាឯកច្ឆន្ទមួយលើវិស័យនានា។

ការទទួលស្គាល់ថាភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ជាកង្វល់ដ៏សំខាន់ដោយថ្នាក់ដឹកនាំថ្នាក់កំពូល នៃស្ថាប័ននានា។ រួមមានក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន គឺជាជោគជ័យមួយ។ ការទទួលស្គាល់នេះបានផ្តល់លទ្ធភាពដល់ការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយលើបទប្បញ្ញត្តិដែលមានស្រាប់ និងការកំណត់អត្តសញ្ញាណ នៃចំនុចខ្វះខាតផ្នែកច្បាប់បន្ថែមដោយបទប្បញ្ញត្តិ ស្តីពីសុខភាពតែមួយដែលជួយសម្រួលដល់ការសម្រិតសម្រាំងឡើងវិញនូវក្របខ័ណ្ឌច្បាប់។

ការបង្កើតក្រុមការងារបច្ចេកទេសពហុវិស័យដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (MS AMR TWG) ក៏ជាសមិទ្ធផលដ៏សំខាន់មួយនៅក្នុងការប្រយុទ្ធភាពស៊ាំនឹងឱសថប្រឆាំងមេរោគរបស់កម្ពុជាដែរ។ ក្រុមការងារនេះត្រូវបានអនុម័តជាផ្លូវការនៅឆ្នាំ២០២៤ ដែលតំណាងឱ្យជំហានដ៏សំខាន់មួយឆ្ពោះទៅរកវិធីសាស្ត្រមួយកាន់តែគ្រប់ជ្រុងជ្រោយ និងកាន់តែងាយស្រួលក្នុងការសម្របសម្រួលចំពោះភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ក្រុមការងារបច្ចេកទេសពហុវិស័យដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ត្រូវបានរៀបចំឡើងដើម្បីជំរុញឱ្យមានភាពបំពេញឱ្យគ្នារវាងក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ដែលក្រសួងនីមួយៗមានប្រធានគណៈកម្មការ ១រូប ដើម្បីធានាបាននូវសហអភិបាលកិច្ច។ អង្គការលេខ នៃក្រុមនេះកំណត់តួនាទីបន្ថែមទៀតជាមួយនឹងអនុប្រធានមួយពីវិស័យនីមួយៗ ដោយធានានូវចនាសម្ព័ន្ធភាពជាអ្នកដឹកនាំពហុវិស័យដែលចង្អុលបង្ហាញគំនិតផ្តួចផ្តើម នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ការដាក់បញ្ចូលលេខាធិការដ្ឋាន សមាជិក និងអ្នកសម្របសម្រួលរួមជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍន៍ បង្ហាញអំពីសមាសភាពដ៏រឹងមាំរបស់ក្រុមការងារនេះ។ ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការនេះ ត្រូវបានរៀបចំឡើងដើម្បីសម្រួលដល់កិច្ចខិតខំប្រឹងប្រែងនានានៅទូទាំងវិស័យ ដោយបង្កើនសមត្ថភាពរបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាប្រឈមដ៏ស្មុគស្មាញរបស់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ប្រកបដោយប្រសិទ្ធភាព។

ទោះជាយ៉ាងណាក៏ដោយ ថ្វីត្បិតតែមានវឌ្ឍនភាពទាំងនេះក៏ដោយមាគ៌ាទៅកាន់ការគ្រប់គ្រងភាពស៊ាំនឹងឱសថប្រឆាំងមេរោគប្រកបដោយប្រសិទ្ធភាព ប៉ុន្តែបញ្ហាប្រឈមនៅតែមាន។ ជាការកត់សម្គាល់ ការខ្វះខាតនៅក្នុងដែនបទប្បញ្ញត្តិនៅតែមាន ជាពិសេសទាក់ទងនឹងបទប្បញ្ញត្តិចំណីសត្វ ហើយបញ្ហាប្រឈមដ៏សំខាន់នៅតែបន្តកើតមានក្នុងការពង្រឹងការអនុវត្តច្បាប់។ ប្រសិទ្ធភាព នៃបទប្បញ្ញត្តិទាំងនេះត្រូវបានរារាំងបន្ថែមទៀតដោយសារការខ្វះការយល់ដឹងទូលំទូលាយក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗនៅគ្រប់កម្រិតទាំងអស់។ ខណៈពេលដែលក្រសួងបរិស្ថានមានការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះបុព្វហេតុនេះ ប៉ុន្តែសមត្ថភាពរបស់ក្រសួងនៅមានកម្រិតសម្រាប់វឌ្ឍនភាពនេះ។ ជាងនេះទៅទៀត ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ មានសារៈសំខាន់សម្រាប់ការតាមដានផលប៉ះពាល់របស់ផែនការសកម្មភាពពហុវិស័យ ប៉ុន្តែមិនត្រូវបានបង្កើតឡើងនៅដើមដំបូងទេ

ដែលជាហេតុបង្កបញ្ហាប្រឈមនានាក្នុងការវាយតម្លៃប្រសិទ្ធភាព នៃផែនការនេះពេញមួយដំណាក់កាល នៃការអនុវត្ត។

ប្រទេសកម្ពុជាក៏បានធ្វើការពិនិត្យឡើងវិញយ៉ាងល្អិតល្អន់លើក្របខ័ណ្ឌច្បាប់ដែលមានស្រាប់រួមទាំងច្បាប់ដែលគ្រប់គ្រងការប្រើប្រាស់ឱសថប្រឆាំងមេរោគលើមនុស្ស សត្វ រុក្ខជាតិ និងបរិស្ថានផងដែរ។ ការពិនិត្យឡើងវិញនេះបានដាក់ចេញនូវមូលដ្ឋានគ្រឹះសម្រាប់ការពង្រឹងការត្រួតពិនិត្យលើការប្រើប្រាស់ឱសថប្រឆាំងមេរោគ និងទប់ស្កាត់ការរីករាលដាល នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ជំហានដ៏សំខាន់មួយ គឺការរួមបញ្ចូលធាតុដែលទាក់ទងនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងផលិតផលសុខភាព។

បន្ថែមពីលើនេះទៀត វាចាំបាច់ណាស់ក្នុងការពង្រីកវិសាលភាព នៃការចូលរួមដោយបញ្ចូលក្រសួងផ្សេងទៀត ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ជាដើម។ ការចូលរួមរបស់ក្រសួងទាំងនេះ ត្រូវបានគេរំពឹងថានឹងពង្រឹងផ្នែកនីតិប្បញ្ញត្តិ នៃការគ្រប់គ្រងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងធានាឱ្យមានការបែងចែកធនធាន និងមូលនិធិកាន់តែប្រសើរឡើង។ កិច្ចសហការអន្តរក្រសួងបែបនេះត្រូវបានគេរំពឹងថានឹងពង្រឹងសមត្ថភាពអនុវត្តច្បាប់ និងអភិបាលកិច្ចទូទៅដោយហេតុថាបានពង្រឹងការឆ្លើយតបរបស់កម្ពុជាចំពោះការគំរាមកំហែងជាសាកល នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

វត្ថុបំណងយុទ្ធសាស្ត្រ និងអន្តរាគមន៍គន្លឹះដែលត្រូវបានស្នើឡើង

វត្ថុបំណងយុទ្ធសាស្ត្រទី១៖ ធានាបាននូវអភិបាលកិច្ចលើភាពស៊ាំនឹងឱសថប្រឆាំងមេរោគ តាមរយៈការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងភាពជាដៃគូនៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងអន្តរជាតិ

អន្តរាគមន៍គន្លឹះ៖

- ១.១ អនុវត្តតាមការណែនាំដែលត្រូវបានផ្តល់ដោយ MS AMR TWG ក្រោមការដឹកនាំរបស់ IMCC-OH ។
- ១.២ ពង្រឹង MS AMR TWG និងពង្រីកវិសាលភាព និងមុខងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ១.៣ ពង្រឹងការកសាងសមត្ថភាពលើភាពស៊ាំនឹងឱសថប្រឆាំងមេរោគ សម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងបង្កលទ្ធភាពឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្តបានចូលរួមក្នុងវេទិកាអន្តរជាតិនានា។
- ១.៤ បង្កើត និងដាក់ឱ្យដំណើរការក្រុមការងាររងពហុជំនាញមួយ ដែលមានការចូលរួមពីផ្នែកពាក់ព័ន្ធទាំងខាងសុខភាពមនុស្ស សុខភាពសត្វ និងសុខភាពបរិស្ថាន ដើម្បីផ្តល់ការណែនាំផ្នែកបច្ចេកទេស និងស្នើវិធីសាស្ត្រស្រាវជ្រាវដែលអាចអនុវត្តបានស្របទៅតាមគោលដៅ និងបរិបទ នៃប្រទេសកម្ពុជា ស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដោយសហការជាមួយស្ថាប័ន និងដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិនានា។

វត្ថុបំណងយុទ្ធសាស្ត្រទី ២៖ ពង្រឹងការអនុវត្ត និងអនុលោមបទប្បញ្ញត្តិ

អន្តរាគមន៍គន្លឹះ៖

- ២.១ ពង្រឹងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌបទប្បញ្ញត្តិដើម្បីគាំទ្រដល់ការបង្ការ និងគ្រប់គ្រងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

២.២ ពង្រឹងប្រសិទ្ធិភាពក្នុងការកសាងសមត្ថភាព និងយន្តការសម្របសម្រួលនៅគ្រប់វិស័យតាមរយៈការអភិវឌ្ឍន៍ធនធានមនុស្ស ឧបករណ៍សំខាន់ៗ និងគោលការណ៍ណែនាំនានា។

វត្ថុបំណងយុទ្ធសាស្ត្រទី ៣៖ កៀរគរធនធានដើម្បីអនុវត្តផែនការសកម្មភាពពហុវិស័យ

អន្តរាគមន៍គន្លឹះ៖

៣.១ ស្វែងរកការគាំទ្រក្នុងការផ្តល់មូលនិធិសម្រាប់ការបង្ការ និងគ្រប់គ្រងភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅក្នុងវិស័យនីមួយៗជាផ្នែក នៃថវិការបស់រដ្ឋាភិបាល។

៣.២ លើកទឹកចិត្តដល់ការរួមវិភាគទានពីអ្នកផ្តល់ជំនួយអន្តរជាតិ តាមរយៈការចូលជួប និងការសរសេរសំណើសុំថវិកា។

វត្ថុបំណងយុទ្ធសាស្ត្រទី ៤៖ អនុវត្តក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃដ៏រឹងមាំមួយ

អន្តរាគមន៍គន្លឹះ៖

៤.១ រចនា និងអនុវត្តក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃដែលបានឯកភាពគ្នាសម្រាប់ផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

៤.២ ចែករំលែករបកគំហើយ នៃការពិនិត្យតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំជាមួយក្រសួងពាក់ព័ន្ធ វិស័យឯកជន និងសាធារណៈដើម្បីធានានូវតម្លាភាព និងបង្កើតការគាំទ្រសម្រាប់ការបង្ការ និងគ្រប់គ្រងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ។

៤.៣ ធ្វើការពិនិត្យលទ្ធផលពាក់កណ្តាលអាណត្តិនៃផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដោយផ្អែកលើរបកគំហើញនៃការពិនិត្យតាមដាន និងវាយតម្លៃ។

ផែនការសកម្មភាពសម្រាប់យុទ្ធសាស្ត្រទី ១

វត្ថុបំណងយុទ្ធសាស្ត្រទី១៖ ធានាបាននូវអភិបាលកិច្ចលើភាពស៊ាំនឹងឱសថប្រឆាំងមេរោគ តាមរយៈការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងភាពជាដៃគូនៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងអន្តរជាតិ

អន្តរាគមន៍គន្លឹះ៖

១.១ អនុវត្តការណែនាំដែលត្រូវបានផ្តល់ដោយ MS AMR TWG ក្រោមការដឹកនាំរបស់ IMCC-OH ។

១.២ ពង្រឹង MS AMR TWG និងពង្រីកវិសាលភាព និងមុខងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ឆ្នាំ	រយៈពេល	សកម្មភាព	ផលសម្រេច	អ្នកទទួលខុសត្រូវ	ថវិកា (គិតជាដុល្លារ)
២០២៥-២០២៩	ប្រចាំឆ្នាំ	ការប្រជុំប្រចាំត្រីមាស MS AMR TWG	កំណត់ហេតុ និងប្រភេទសកម្មភាព	ប្រធាន MS AMR TWG	២៥.០០០
២០២៦	ឆមាសទី១	អនុម័ត ToR សម្រាប់ MS AMR TWG & បង្កើតយន្តការសម្របសម្រួលថ្នាក់ខេត្ត	ToR ត្រូវបានអនុម័ត	MS AMR TWG	១៥.០០០
២០២៦ - ២០២៩	ប្រចាំឆ្នាំ	រៀបចំសន្និសីទប្រចាំឆ្នាំអំពីAMR រៀបចំសន្និសីទប្រចាំឆ្នាំAMRដើម្បីតាមដាន	របាយការណ៍សន្និសីទបានផ្សព្វផ្សាយ	MoH, MAFF, MoE (ដោយប្តូរវេណគ្នា)	៧៥.០០០

		ការអនុវត្ត MSAP-AMR			
២០២៦-២០២៩	ប្រចាំឆ្នាំ	កំណត់យន្តការ នៃការទំនាក់ទំនងរវាង TWGs និងជាមួយ IMCC-OH	សារាចរវាងក្រសួងផ្សេងៗគ្នា	MS AMR TWG	១០.០០០
២០២៦-២០២៩	ប្រចាំឆ្នាំ	បង្កើតគោលការណ៍សង្ខេបអំពី AMR	សង្ខេបគោលនយោបាយដែលបានចេញផ្សាយ	MS AMR TWG	១៥.០០០
២០២៨	ឆមាសទី១	ការពិនិត្យលទ្ធផលពាក់កណ្តាលអាណត្តិ នៃ MSAP AMR	របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ	MS AMR TWG	២០.០០០
២០២៦-២០២៧	ប្រចាំឆ្នាំ	បង្កើតគណៈកម្មការសុខភាពតែមួយថ្នាក់ក្រោមជាតិមួយក្រោមការដឹកនាំរបស់អភិបាលខេត្ត	គណៈកម្មាធិការសុខភាពតែមួយថ្នាក់ខេត្តត្រូវបានបង្កើត	ខេត្តដែលបានជ្រើសរើស	៣០.០០០
២០២៦-២០២៩	កំពុងបន្ត	បង្កើត ឬពង្រឹងវេទិកាចែករំលែកព័ត៌មានទិន្នន័យឌីជីថល	ព័ត៌មាន ឬរបាយការណ៍បានចែករំលែកទៀងទាត់	MS AMR TWG	១០០.០០០

១.៣ ពង្រឹងការកសាងសមត្ថភាពលើភាពស៊ាំនឹងឱសថប្រឆាំងមេរោគ សម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងបង្កលទ្ធភាពឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្តបានចូលរួមក្នុងវេទិកាអន្តរជាតិនានា។

ឆ្នាំ	រយៈពេល	សកម្មភាព	ផលសម្រេច	អ្នកទទួលខុសត្រូវ	ថវិកា (គិតជាដុល្លារ)
២០២៦-២០២៩	ប្រចាំឆ្នាំ	សិក្ខាសាលាពិនិត្យគោលនយោបាយ AMR ឡើងវិញជាបន្តបន្ទាប់	របាយការណ៍សិក្ខាសាលាជាមួយអនុសាសន៍គោលនយោបាយ	MS AMR TWG	២០.០០០
២០២៧-២០២៩	ប្រចាំឆ្នាំ	ការឧបត្ថម្ភសម្រាប់ការចូលរួមក្នុងវេទិកា AMR សកល និងតំបន់	របាយការណ៍ស្តីពីការចូលរួមវេទិកាអន្តរជាតិ និងការរៀនសូត្រសំខាន់ៗ	MoH, MAFF, MoE	៥០.០០០

១.៤ បង្កើត និងដាក់ឱ្យដំណើរការក្រុមការងាររងពហុជំនាញមួយ ដែលមានការចូលរួមពីផ្នែកពាក់ព័ន្ធទាំងខាងសុខភាពមនុស្ស សុខភាពសត្វ និងសុខភាពបរិស្ថាន ដើម្បីផ្តល់ការណែនាំផ្នែកបច្ចេកទេស និងស្នើវិធីសាស្ត្រស្រាវជ្រាវដែលអាចអនុវត្តបានស្របទៅតាមគោលដៅ និងបរិបទ នៃប្រទេសកម្ពុជា ស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដោយសហការជាមួយស្ថាប័ន និងដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិនានា។

ឆ្នាំ	រយៈពេល	សកម្មភាព	ផលសម្រេច	អ្នកទទួលខុសត្រូវ	ថវិកា (គិតជាដុល្លារ)
២០២៦-២០២៩	ឆមាសទី១	បង្កើតក្រុមការងាររងពហុជំនាញមួយ ដែលមានការចូលរួមពីផ្នែកពាក់ព័ន្ធទាំងតំណាងមកពី MOH ដូចជាមន្ទីរពេទ្យដែលអនុវត្តការងារ AMR, ខាងមន្ទីរពិសោធន៍ជាតិ (NIPH និងវិទ្យាស្ថាន	ឯកភាពលើការតែងតាំងដោយមានតួនាទី និងការកិច្ចច្បាស់លាស់ ដើម្បីផ្តល់ការណែនាំផ្នែកបច្ចេកទេស និងស្នើវិធីសាស្ត្រស្រាវជ្រាវដែលអាចអនុវត្តបានស្របទៅតាមគោលដៅ និងបរិប	MS AMR TWG	១០.០០០

		ប៉ាស្ទ័រកម្ពុជា) អ្នកជំនាញស្រាវជ្រាវសុខភាពសាធារណៈ (NIPH និងUHS), តំណាងក្រុមការងារ AMS/AMC និង IPC និងតំណាងមកពី MAFF និង MOE	ទំនៃប្រទេសកម្ពុជា ស្តីពីភាពសុំនឹងឱសថប្រឆាំងមេរោគ ដោយសហការជាមួយស្ថាប័ន និងដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិនានា។		
២០២៧-២០២៩	ជាប់ជាបន្ត	រៀបចំកិច្ចប្រជុំជាទៀងទាត់ ឬកិច្ចប្រជុំពិសេសរបស់ក្រុមការងាររង មុនកិច្ចប្រជុំរបស់ MS-AMR-TWG ដែលប្រជុំរៀងរាល់ប្រាំមួយខែម្តង	ធ្វើរបាយការណ៍នៃកិច្ចប្រជុំ និងដាក់ជូន MS AMR TWG	MoH, MAFF, MoE	៥0.000
២០២៧-២០២៩	ជាប់ជាបន្ត	ផ្តល់ការគាំទ្រដល់ក្រុមការងារបច្ចេកទេស MS-AMR-TWG ក្នុងការវាយតម្លៃពីផលជះ នៃការអនុវត្តគម្រោង AMR នៅកម្ពុជាតាមតម្រូវការ	របាយការណ៍វាយតម្លៃ រួមទាំងអនុសាសន៍	MoH, MAFF, MoE	៣0.000

វត្ថុបំណងយុទ្ធសាស្ត្រទី ២៖ ពង្រឹងការអនុវត្ត និងអនុលោមបទបញ្ញត្តិ

អន្តរាគមន៍គន្លឹះ៖

២.១ ពង្រឹងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌបទបញ្ញត្តិ ដើម្បីគាំទ្រដល់ការបង្ការ និងគ្រប់គ្រងភាពសុំនឹងឱសថប្រឆាំងមេរោគ។

ឆ្នាំ	រយៈពេល	សកម្មភាព	ផលសម្រេច	អ្នកទទួលខុសត្រូវ	ថវិកា (គិតជាដុល្លារ)
២០២៦-២០២៨	ឆមាសទី១	រៀបចំអនុវត្ត ឬ/និងបញ្ចប់ និងវាយតម្លៃអនុសាសន៍ពីរបាយការណ៍វាយតម្លៃផ្លូវច្បាប់ សុខភាពតែមួយ	របាយការណ៍វាយតម្លៃផ្នែកច្បាប់សុខភាពតែមួយ	MAFF, MoH, MoE	៥0.000
២០២៦៧-២០២៩	ឆមាសទី២	ការអនុវត្តអនុសាសន៍ នៃរបាយការណ៍វាយតម្លៃផ្លូវច្បាប់ សុខភាពតែមួយ	(អាស្រ័យលើអនុសាសន៍)	MoH, MAFF, MoE	១00.000
២០២៦	ឆមាសទី២	បង្កើតឬ/និងកែសម្រួលបទប្បញ្ញត្តិ និងគោលការណ៍ណែនាំទាក់ទងនឹងការបង្ការ និងគ្រប់គ្រង AMR	បទបញ្ញត្តិស្តីពីការគ្រប់គ្រងឱសថត្រូវបានកែតម្រូវ	MS AMR TWG	៨0.000

២.២ ពង្រឹងប្រសិទ្ធិភាពក្នុងការកសាងសមត្ថភាព និងយន្តការសម្របសម្រួលនៅគ្រប់វិស័យតាមរយៈការអភិវឌ្ឍធនធានមនុស្ស ឧបករណ៍សំខាន់ៗ និងគោលការណ៍ណែនាំនានា។

ឆ្នាំ	រយៈពេល	សកម្មភាព	ផលសម្រេច	អ្នកទទួលខុសត្រូវ	ថវិកា (គិតជាដុល្លារ)
២០២៦-២០២៩	ប្រចាំឆ្នាំ	ធ្វើបច្ចុប្បន្នភាព និងពង្រឹងគោលនយោបាយ គោលការណ៍ណែនាំ និង	ឯកសារណែនាំទាក់ទងនឹង AMRត្រូវបានធ្វើបច្ចុប្បន្នភាព	MoH, MAFF, MoE	៨0.000

		SOP ដែលទាក់ទងនឹង AMR ដែលមានស្រាប់នៅគ្រប់វិស័យ			
២០២៧	ឆមាសទី២	ពង្រឹងបទប្បញ្ញត្តិដើម្បីដាក់វិន័យ/ពិន័យចំពោះការបំពានដែលទាក់ទងនឹងAMR	បានធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិសម្រាប់ការបំពានដែលទាក់ទងនឹង AMR	MoH, MAFF, MoE, MoJ	១៥.000
២០២៨	ឆមាសទី២	ប៉ាន់ប្រមាណ និងវាយតម្លៃផលប៉ះពាល់ នៃគោលនយោបាយ និងបទប្បញ្ញត្តិអំពី AMR	គោលនយោបាយ និងបទប្បញ្ញត្តិរបស់ AMR របាយការណ៍ផលប៉ះពាល់	MS AMR TWG	៣0.000

វត្ថុបំណងយុទ្ធសាស្ត្រទី ៣៖ កៀរគរធនធានដើម្បីអនុវត្តផែនការសកម្មភាពពហុវិស័យ

អន្តរាគមន៍គន្លឹះ៖

៣.១ ស្វែងរកការគាំទ្រក្នុងការផ្តល់មូលនិធិសម្រាប់ការបង្ការ និងគ្រប់គ្រងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នៅក្នុងវិស័យនីមួយៗ ជាផ្នែកនៃថវិការបស់រដ្ឋាភិបាល។

ឆ្នាំ	រយៈពេល	សកម្មភាព	ផលសម្រេច	អ្នកទទួលខុសត្រូវ	ថវិកា (គិតជាដុល្លារ)
២០២៦-២០២៩	ប្រចាំឆ្នាំ	បង្កើតនវានុវត្តន៍សម្រាប់ការវិនិយោគក្នុងការប្រយុទ្ធនឹង AMR	ឯកសារករណីអាជីវកម្មគ្រប់ជ្រុងជ្រោយ	MS AMR TWG	១00.000
២០២៧	ឆមាសទី២	ការរួមបញ្ចូលមូលនិធិ AMR ទៅក្នុងដំណើរការថវិកាជាតិ	ខ្ទង់ថវិកាសម្រាប់ AMR ដាក់ក្នុងថវិកាជាតិ	MoH, MAFF, MoE, MEF	១៥.000
២០២៨	ឆមាសទី២	រៀបចំសិក្ខាសាលាស្តីពីការស្វែងរកការគាំទ្រ និងការកៀរគរធនធានដើម្បីផ្តល់មូលនិធិដល់សកម្មភាពអនុវត្ត MSAP-AMR	សិក្ខាសាលាត្រូវបានរៀបចំ	MoH, MAFF, MoE	៣0.000
២០២៨-២០២៩	ឆមាសទី១	ការរួមបញ្ចូលមូលនិធិ AMR ទៅក្នុងដំណើរការថវិកាថ្នាក់ក្រោមជាតិ	ខ្ទង់ថវិកា AMR រួមបញ្ចូលគ្នានៅក្នុងថវិកាថ្នាក់ក្រោមជាតិ	MoH, MAFF, MoE, MoI, MEF	៥0.000

៣.២ លើកទឹកចិត្តដល់ការរួមវិភាគទានពីអ្នកផ្តល់ជំនួយអន្តរជាតិតាមរយៈការចូលជួប និងការសរសេរសំណើសុំថវិកា និងបង្កើតភាពជាដៃគូយុទ្ធសាស្ត្រជាមួយស្ថាប័នឯកជន និងដៃគូអភិវឌ្ឍន៍។

